# ព្រឹត្តិបត្រព័ត៌មាន

លេខ ៣២ ខែមេសា-ធ្នូ ឆ្នាំ២០២០




សម្តេចក្រឡាហោម ស ខេង មានប្រសាសន៍ក្នុងពិធីបើកសិក្ខាសាលាជាតិពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទាន។ រឿន សារ៉ុន

## រាជរដ្ឋាភិបាលកម្ពុជាកំណត់ចក្ខុវិស័យរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០)

រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមកំណត់ចក្ខុវិស័យសម្រាប់រៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ២០២១-២០៣០ តាមរយៈការរៀបចំសិក្ខាសាលាជាតិពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទាន កាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានវត្តមានអ្នកចូលរួមប្រមាណ ២៧០ រូប ជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។

នៅក្នុងពិធីបើកសិក្ខាសាលា សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.អ.ប បានកោតសរសើរចំពោះអ្នកពាក់ព័ន្ធដែលបានផ្តល់ការគាំទ្រនិងចូលរួមអនុវត្តយ៉ាងសកម្មក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានជម្រុញឱ្យកំណែទម្រង់នេះមានការវិវឌ្ឍជាជំហានៗ ស្របតាមដំណាក់កាលនីមួយៗដែលបានកំណត់នៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ព្រមទាំងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល ១០ ឆ្នាំដំបូង ២០១០-២០២០ ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

តទៅទំព័រ ៤

សហការនិងគាំទ្រដោយ:




ឯកឧត្តម ប៉ា សុជាតិវង្ស មានប្រសាសន៍នៅក្នុងវគ្គបណ្តុះបណ្តាលគណៈកម្មការ ទំនាក់ទំនងសាធារណៈ របស់សមាគមជាតិ នាថ្ងៃទី១០ វិច្ឆិកា ឆ្នាំ២០២០ ។ ឈឹម សុភាគ

# ឯកឧត្តម ប៉ា សុជាតិវង្ស៖ សមាគមជាតិខិតខំអនុវត្ត តួនាទីជាតំណាងសំឡេងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត

ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានគូសបញ្ជាក់ជាថ្មីម្តងទៀតថា សមាគមជាតិបានខិតខំអនុវត្តតួនាទីរបស់ខ្លួន ជាតំណាងសំឡេង និងជាអ្នកវេចខ្ចប់នូវរាល់បញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការ អនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីដាក់ជូន គ.ជ.អ.ប អនុលោមតាមច្បាប់ជាធរមាន។

ឯកឧត្តម ប៉ា សុជាតិវង្ស បានលើកឡើងដូច្នេះ នាថ្ងៃទី១០ វិច្ឆិកា នៅក្នុង ពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីការងារទំនាក់ទំនងសាធារណៈនិងជំនាញអ្នកនាំ ពាក្យដើម្បីលើកកម្ពស់សមត្ថភាពគណៈទំនាក់ទំនងសាធារណៈរបស់សមាគម ជាតិ ដោយឯកឧត្តមប្រធានបញ្ជាក់ថា៖ “យើងចង់ឱ្យការជួបជុំនានារបស់ សមាគមជាតិ អាចប្រមូលផ្តុំនូវបញ្ហាប្រឈមរួមរបស់ក្រុមប្រឹក្សា ដើម្បីដាក់ជូន គ.ជ.អ.ប បញ្ចូលទៅក្នុងកម្មវិធីជាតិ [កម្មវិធីជាតិ២០២១-២០៣០]”។

នៅក្នុងតួនាទីតំណាងសំឡេងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត សមាគម ជាតិបានចូលរួមក្នុងកិច្ចប្រជុំរបស់ គ.ជ.អ.ប ចាប់តាំងពីឆ្នាំ២០១៤ និងជាសមាជិក ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ចាប់តាំងពីឆ្នាំ២០១៦។ បន្ថែមលើនេះ សមាគមជាតិកាលពីខែសីហា ឆ្នាំ២០២០ បានចាត់តាំងតំណាងចូលរួមជាសមាជិកអនុគណៈកម្មាធិការចំណុះ គ.ជ.អ.ប រួមមាន៖ ១. អនុគណៈកម្មាធិការមុខងារ និងធនធាន ២. អនុគណៈកម្មាធិការ កិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ ៣. អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ ក្រោមជាតិ ៤. អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍រដ្ឋបាលថ្នាក់ក្រោមជាតិ និង ៥. អនុគណៈកម្មាធិការសេវាកម្មយុត្តិធម៌។

ជាមួយគ្នានេះដែរ សមាគមជាតិបានធ្វើការពង្រឹងស្ថាប័នរបស់ខ្លួន មានជាអាទិ៍៖ ការកែសម្រួលសមាសភាពកម្រងទាំង ៥ និងគណៈកម្មការជំនាញ ទាំង ៣ គឺ៖ ១. គណៈកម្មការទំនាក់ទំនងសាធារណៈ ២. គណៈកម្មការ អភិវឌ្ឍន៍ សមត្ថភាព ៣. គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ។

គណៈកម្មការនីមួយៗបានរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីកំណត់ទិស ដៅការងារ ជួយសមាគមជាតិ ក្នុងការអនុវត្តសកម្មភាព ដើម្បីលើកកម្ពស់ សមត្ថភាព និងការពារផលប្រយោជន៍ស្របច្បាប់របស់ក្រុមប្រឹក្សារាជធានី ខេត្ត។

**សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត**
**ប្រធាន** ឯកឧត្តម ប៉ា សុជាតិវង្ស
**អនុប្រធានអចិន្ត្រៃយ៍** ឯកឧត្តម យឹម សុខុម
**អនុប្រធាន** ឯកឧត្តម ម៉ៅ ភិរុណ
លោកជំទាវ មុំ ក្រសាល,ឯកឧត្តម ឡុង សុវណ្ណ
ឯកឧត្តម អ៊ុយ រី , ឯកឧត្តម ខួត ផន
ឯកឧត្តម កាយ សំរួម , ឯកឧត្តម ម៉ែន ង៉ុយ
ឯកឧត្តម កៅ ចេស្តា, លោកជំទាវ ប្រាក់ ពុទ្ធី
ឯកឧត្តម ចិន ញៀន , ឯកឧត្តម ផន ប៊ុន

**សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន**
**ប្រធាន** ឯកឧត្តម សយ កុសល
**អនុប្រធានអចិន្ត្រៃយ៍** លោកស្រី ស៊ី តួន
**អនុប្រធាន** លោក គង់ ឆេង
លោក យុង ហួត, លោក គៀង សេងគី
លោក សំរិទ្ធិ អេង, លោក ស៊ីវ យុត
លោក យស់ យឿន, លោកស្រី ហេង ស្រីពៅ
លោក ម៉ាក សុខឿន, លោកស្រី ខាញ់ សូរី
លោក ពៅ បឿន, លោក សុខ រស្មី

**អគ្គលេខាធិការ**
លោក ប៉ុក សុគន្ធដារ៉ា
**អគ្គលេខាធិការរង**
លោក ឈឹម សុភាគ

ព្រឹត្តិបត្រព័ត៌មាន
**និពន្ធនាយក**
ឈឹម សុភាគ
**ក្រុមជំនួយការផលិត**
សយ សិទ្ធិកា, ខុន កន្និដ្ឋា
សុទ្ធ ចាន់នីកា
**អគ្គលេខាធិការដ្ឋាន**
ស្ថិតក្នុងបរិវេណព្រឹទ្ធសភា (វិមានរដ្ឋចំការមន)
មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារៈ ០២៣ ២៣៨ ០៨០
អ៊ីម៉ែលៈ darapok@online.com.kh
គេហទំព័រៈ www.clga.org.kh

# គណៈកម្មការអភិវឌ្ឍន៍សមត្ថភាព និងគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមាររបស់សមាគមជាតិរៀបចំកិច្ចប្រជុំលើកទី១ កំណត់ទិសដៅការងារ



*សមាសភាពគណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នៃសមាគមជាតិ។*



*សមាសភាពគណៈកម្មការអភិវឌ្ឍន៍សមត្ថភាព នៃសមាគមជាតិ។ ឈឹម សុភាគ*

គណៈ កម្មការអភិវឌ្ឍន៍សមត្ថភាព និងគណៈ កម្មការទទួលបន្ទុកកិច្ចស្ត្រីនិងកុមារ (គ. ទ.ស.ក) របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានរៀបចំកិច្ចប្រជុំលើកទី១ ដើម្បីកំណត់ទិសដៅការងាររបស់ខ្លួន។

ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានចូលរួមមានមតិសំណេះសំណាលនិងបើកកិច្ចប្រជុំគណៈ កម្មការ ទាំងពីរ ដែលគណៈ កម្មការនីមួយៗមានសមាសភាពចំនួន ១១ រូប (សូមអានសមាសភាពនៅទំព័រ ៧)។

ក្នុងមតិបើកកិច្ចប្រជុំគណៈ កម្មការអភិវឌ្ឍន៍សមត្ថភាព ឯកឧត្តម ប៉ា សុជាតិវង្ស បានគូសបញ្ជាក់ថា ការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សារាជធានី ខេត្ត នាពេលបច្ចុប្បន្ននេះ មិនទាន់បានពេញលេញស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅឡើយ។ ហេតុនេះ ឯកឧត្តមប្រធានចង់បានការសិក្សាផ្លូវច្បាប់មួយជាក់លាក់ដើម្បីជាមូលដ្ឋានសម្រាប់សមាគមជាតិស្នើសុំទៅ គ.ជ.អ.ប រៀបចំបញ្ជីសកម្មភាព ថាតើមុខងារណាជា**មុខងារជាកាតព្វកិច្ច** ហើយមុខងារណាជា**មុខងារជាជម្រើស**របស់ក្រុមប្រឹក្សា។

លោកជំទាវ មុំ ក្រសាល អនុប្រធានសមាគមជាតិ និងជាប្រធានគណៈ កម្មការអភិវឌ្ឍន៍សមត្ថភាព បានដឹកនាំកិច្ចប្រជុំនាថ្ងៃទី ១០ សីហា ដោយផ្ដោតលើការឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈម និងការកំណត់តម្រូវការបណ្ដុះបណ្ដាលកសាងសមត្ថភាពដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងការរៀបចំផែនការសកម្មភាពការងាររបស់គណៈ កម្មការ។

ជាលទ្ធផល គណៈ កម្មការអភិវឌ្ឍន៍សមត្ថភាពបានកំណត់មេរៀនចំនួន ៣ ជាអាទិភាពសម្រាប់ធ្វើការបណ្ដុះបណ្ដាលជូនដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត៖ **ទី១** ការគ្រប់គ្រងរដ្ឋបាលខេត្ត តាមបែបវិមជ្ឈការ **ទី២** ការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង**ទី៣** ទំនាក់ទំនងអន្តររដ្ឋបាលនិងផ្ទៃក្នុងរដ្ឋបាល ដោយសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

ដើម្បីពង្រឹងតួនាទីនៅក្នុងកិច្ចដំណើរការបណ្ដុះបណ្ដាលសមាជិកក្រុមប្រឹក្សារាជធានី ខេត្តនៅទូទាំងប្រទេស គណៈ កម្មការអភិវឌ្ឍន៍សមត្ថភាពបានកំណត់ប្រធានបទពីរ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន៖ ១.ជំនាញសម្របសម្រួល និង ២.ជំនាញធ្វើបទបង្ហាញ និងការនិយាយជាសាធារណៈ។

គណៈ កម្មការអភិវឌ្ឍន៍សមត្ថភាពត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៧ ក្នុងគោលបំណងផ្ដល់យោបល់ និងជួយការងារបច្ចេកទេសពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត។

លោកជំទាវ នួន នារតី ប្រធាន គ.ក.ស.ក ខេត្តកណ្ដាល និងជាប្រធាន គ. ទ.ស.ក បានដឹកនាំកិច្ចប្រជុំនាថ្ងៃទី១ កញ្ញា ដោយបានឆ្លុះបញ្ចាំងអំពីការអនុវត្តការងាររបស់ គ.ក.ស.ក រាជធានី ខេត្ត (ការអនុវត្តល្អ បញ្ហាប្រឈមនិងសំណើដំណោះស្រាយ) និងការរៀបចំផែនការសកម្មភាពការងាររបស់គណៈ កម្មការ។

ជាលទ្ធផល គ. ទ.ស.ក បានសម្រេច៖ **ទី១** ស្នើសុំសមាគមជាតិ ជួយជម្រុញក្រសួងស្ថាប័នពាក់ព័ន្ធធ្វើការវិភាជថវិកាសម្រាប់ គ.ក.ស.ក និង គ.ក.ន.ក ឱ្យបានទាន់ពេលវេលា ដើម្បីអនុវត្តមុខងារឱ្យកាន់តែប្រសើរឡើង **ទី២** បន្តស្វែងរកការគាំទ្រពីរដ្ឋបាលខេត្ត និងដៃគូអភិវឌ្ឍន៍ដល់ដំណើរការរបស់ គ.ក.ស.ក **ទី៣** រៀបចំការបណ្ដុះបណ្ដាលប្រធាន អនុប្រធាន គ.ក.ស.ក ២៥ រាជធានី ខេត្ត ស្ដីពី "ការប្រឹក្សាយោបល់ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ" **ទី៤** សម្របសម្រួលប្រមូលព័ត៌មានអំពីបញ្ហាប្រឈមរបស់ គ.ក.ស.ក។

ឯកឧត្តម ប៉ា សុជាតិវង្ស បានថ្លែងនៅក្នុងមតិបើកកិច្ចប្រជុំ គ.ទ.ស.ក ដោយបញ្ជាក់ថា គ.ក.ស.ក ២៥ រាជធានី ខេត្ត មានតួនាទីសំខាន់ផងដែរ រួមចំណែកនៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបានជោគជ័យ។

គ. ទ.ស.ក ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្ដល់យោបល់ និងជួយការងារបច្ចេកទេសពាក់ព័ន្ធនឹងការងារស្ត្រី និងកុមាររបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត៕

តមកពីទំព័រ ១

ក្នុងសុន្ទរកថាបិទសិក្ខាសាលារបស់ **សម្តេចតេជោ ហ៊ុន សែន** ដែលអានទាំងស្រុងដោយ **សម្តេចក្រឡាហោម ស ខេង** បានផ្តល់នូវគោលការណ៍ណែនាំ ៥ ចំណុចសម្រាប់ការកែទម្រង់វិមជ្ឈការដែលត្រូវរួមគ្នាសម្រេចឱ្យបានក្នុងរយៈពេល ១០ ឆ្នាំបន្តទៀតដូចខាងក្រោម៖

**ទីមួយ៖ អំពីការពង្រឹងការគ្រប់គ្រងកិច្ចដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** រាជរដ្ឋាភិបាលនឹងបន្តជំរុញការកែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗដទៃទៀត។

**ទីពីរ៖ អំពីការពង្រឹងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន** ដើម្បីរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានរយៈពេល ១០ ឆ្នាំបន្តទៀត **សម្តេចតេជោ ហ៊ុន សែន** បានផ្តល់នូវគោលការណ៍ណែនាំ ៣ ចំណុច៖ ១.ការសិក្សា និងការរៀបចំរាជធានីភ្នំពេញឱ្យក្លាយជាទីក្រុងមេត្រូប៉ូលីទែន ២.ការរៀបចំរដ្ឋបាលក្រុង ស្រុកនានាទៅជារដ្ឋបាលមូលដ្ឋានជួរមុខ ៣.ការសិក្សា និងការរៀបចំរដ្ឋបាលខេត្ត ឱ្យមានចរិកលក្ខណៈជារដ្ឋបាលតំបន់។

**ទីបី៖ អំពីការពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** មន្ត្រីជំនាញបច្ចេកទេសភាគច្រើននឹងត្រូវផ្ទេរពីក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ ដើម្បីដាក់ពង្រាយឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទីបួន៖ អំពីការផ្ទេរធនធានហិរញ្ញវត្ថុទៅរដ្ឋបាលថ្នាក់ក្រោមជាតិ** រាជរដ្ឋាភិបាលនឹងគិតគូរពិចារណាអំពីការប្រគល់នូវមូលដ្ឋានពន្ធ និងមិនមែនសារពើពន្ធបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំបង្កើត "កញ្ចប់ថវិកាពិសេស" សម្រាប់គាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

**ទីប្រាំ៖ ការរៀបចំនិងពង្រឹងប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ធានាការផ្តល់សេវាសាធារណៈឆាប់រហ័ស។

# ថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលជួបក្រុមទីប្រឹក្សាជាតិ-អន្តរជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប





*ក្រុមទីប្រឹក្សាជាតិ-អន្តរជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប បានជួបជាមួយថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងព្រឹទ្ធសភា។*

ថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលជួបប្រជុំប្រឹក្សាយោបល់ជាមួយក្រុមទីប្រឹក្សាជាតិ-អន្តរជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិភាក្សានិងប្រមូលធាតុចូលនៅក្នុងការរៀបចំតាក់តែងឯកសារលម្អិតនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (ឆ្នាំ២០២១-២០៣០)។

បើតាមក្រុមទីប្រឹក្សាដឹកនាំដោយលោកបណ្ឌិត Peter Koeppinger ការរៀបចំកម្មវិធីជាតិដំណាក់កាលទី២ នេះ គឺផ្អែកទៅលើសេចក្តីព្រាងឯកសារទស្សនទានស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០២១-២០៣០។

កម្មវិធីជាតិដំណាក់កាលទី២ នេះនឹងត្រូវបានរៀបចំឡើងជាសមាសភាពចំនួន ៥ ក្នុងនោះ **សមាសភាពទី១ គឺការដឹកនាំនិងការគ្រប់គ្រងការងារកំណែទម្រង់** ដែលកិច្ចការជាអាទិភាពមួយគឺ ការពង្រឹង និងការគាំទ្រដល់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់នៃភាពជាតំណាងឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស សម្រាប់ផ្តល់ការគាំទ្រ ការការពារ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងជំនួបនាថ្ងៃទី២១ តុលា បានគូសបញ្ជាក់ច្បាស់ជូនក្រុមទីប្រឹក្សាអំពីបញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹង "ការផ្ទេរមុខងារមិនដាច់ខាត" "ស្មារតីច្បាប់និងការអនុវត្តជាក់ស្តែង" និង "ខ្សែរគណនេយ្យភាពរបស់ក្រុមប្រឹក្សារាជធានី ខេត្ត"។

ឯកឧត្តម សយ កុសល ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន បានជម្រាបជូនក្រុមទីប្រឹក្សានាថ្ងៃទី២២ តុលា ដោយបានលើកឡើងថា សម្ព័ន្ធភាពជាតិមានមហិច្ឆិតាចង់បានការពង្រឹងតួនាទីប្រកបដោយប្រសិទ្ធភាពនៅក្នុង "ការតស៊ូមតិ" និង "កសាងសមត្ថភាពសមាជិកក្រុមប្រឹក្សា" ដើម្បីឱ្យក្រុមប្រឹក្សាបំពេញមុខងាររបស់ខ្លួនឱ្យបានពេញលេញ ដោយបានស្នើសុំការពង្រឹងចីរភាពហិរញ្ញវត្ថុរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

# សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិចាត់តាំងតំណាងរបស់ខ្លួន ចូលជាសមាជិកអនុគណៈកម្មាធិការទាំង ៥ ចំណុះ គ.ជ.អ.ប

អនុគណៈកម្មាធិការចំណុះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ចំនួន ៥ ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ ១១១ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០២០ ដែល អនុគណៈកម្មាធិការនីមួយៗ មានសមាសភាពចំនួន ៧ រូប រួមមាន៖ ប្រធាន ១ រូប អនុប្រធានអចិន្ត្រៃយ៍ ១ រូប អនុប្រធាន ២ រូប និងសមាជិកចំនួន ៣ រូប ក្នុងនោះតំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ២ រូប ជាសមាជិក។

**១. អនុគណៈកម្មាធិការមុខងារ និងធនធាន** មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប លើកិច្ចការនានាពាក់ព័ន្ធនឹងប្រព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**២. អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ** មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប លើកិច្ចការពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប លើកិច្ចការនានាពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៤. អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ** មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប លើកិច្ចការនានាពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៥. អនុគណៈកម្មាធិការសេវាកម្មយុត្តិធម៌** មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប លើកិច្ចការនានាពាក់ព័ន្ធនឹងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អនុគណៈកម្មាធិការនីមួយៗត្រូវមានកិច្ចប្រជុំយ៉ាងតិចបី (០៣) ដងក្នុងមួយឆ្នាំ។ សេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនីមួយៗអាស្រ័យទៅលើការកំណត់របស់ប្រធានអនុគណៈកម្មាធិការ ឬផ្អែកលើសំណើរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ឬផ្អែកតាមការណែនាំរបស់ប្រធាន គ.ជ.អ.ប។

កិច្ចប្រជុំអនុគណៈកម្មាធិការអាចយកជាការបាន លុះត្រាតែមានវត្តមានសមាជិកអនុគណៈកម្មាធិការចូលរួមកិច្ចប្រជុំលើសពីពាក់កណ្តាលនៃសមាជិកអនុគណៈកម្មាធិការទាំងមូល។ សមាជិកអនុគណៈកម្មាធិការអាចចាត់តំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមជំនួសក្នុងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការ។

រាល់ការសម្រេចរបស់អនុគណៈកម្មាធិការនៅក្នុងការផ្តល់យោបល់ ឬអនុសាសន៍នានាជូន គ.ជ.អ.ប ត្រូវធ្វើឡើងដោយមានការឯកភាពគ្នាផ្អែកលើសំឡេងគាំទ្រដាច់ខាតនៃចំនួនសមាជិករបស់អនុគណៈកម្មាធិការដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ។

អនុគណៈកម្មាធិការនីមួយៗត្រូវរៀបចំ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំនីមួយៗជូនប្រធាន គ.ជ.អ.ប៕

| សមាសភាពតំណាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិជាសមាជិកអនុគណៈកម្មាធិការចំណុះ គ.ជ.អ.ប | | |
|---|---|---|
| **១. អនុគណៈកម្មាធិការមុខងារ និងធនធាន** | | **លេខទូរស័ព្ទ** |
| ឯកឧត្តម យឹម សុខុម | អនុប្រធានអចិន្ត្រៃយ៍សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | 012 811 117 |
| លោក យុង ហួត | អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 012 329 427 |
| **២. អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ** | | |
| ឯកឧត្តម អ៊ុយ រី | អនុប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | 012 508 180 |
| លោក គៀង សេងគី | អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 012 958 557 |
| **៣. អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** | | |
| ឯកឧត្តម ម៉ែន ង៉យ | អនុប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | 012 588 060 |
| លោក សំរិទ្ធិ អេង | អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 012 832 467 |
| **៤. អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍រដ្ឋបាលថ្នាក់ក្រោមជាតិ** | | |
| លោកជំទាវ មុំ គ្រសាល | អនុប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | 012 805 471 |
| លោក ស៊ី យុត | អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 012 985 687 |
| **៥. អនុគណៈកម្មាធិការសេវាកម្មយុត្តិធម៌** | | |
| ឯកឧត្តម ម៉ៅ ភិរុណ | អនុប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត | 012 230 360 |
| លោកស្រី ស៊ី តួន | អនុប្រធានអចិន្ត្រៃយ៍សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ | 012 870 336 |

# ថ្នាក់ដឹកនាំសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត អាណត្តិទី២



ឯកឧត្តម ប៉ា សុជាតិវង្ស
ប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ
លេខទូរស័ព្ទ 077 775 757



លោកជំទាវ មុំ គ្រសាល
អនុប្រធានសមាគមជាតិ
សមាជិកាក្រុមប្រឹក្សារាជធានីភ្នំពេញ
លេខទូរស័ព្ទ 012 805 471



ឯកឧត្តម យឹម សុខុម
អនុប្រធានអចិន្ត្រៃយ៍សមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ
លេខទូរស័ព្ទ 012 811 117



ឯកឧត្តម ម៉ៅ ភិរុណ
អនុប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តកណ្ដាល
លេខទូរស័ព្ទ 012 230 360



ឯកឧត្តម ឡុង សុវណ្ណ
អនុប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ
លេខទូរស័ព្ទ 011 840 013/012 961 026



ឯកឧត្តម អ៊ុយ រី
អនុប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តបាត់ដំបង
លេខទូរស័ព្ទ 012 508 180



ឯកឧត្តម ខួត ផន
អនុប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម
លេខទូរស័ព្ទ 012 823 925



ឯកឧត្តម កាយ សំរួម
អនុប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តកោះកុង
លេខទូរស័ព្ទ 097 981 3388



ឯកឧត្តម ម៉ែន ង៉ុយ
អនុប្រធានសមាគមជាតិ
ប្រធានក្រុមប្រឹក្សាខេត្តមណ្ឌលគិរី
លេខទូរស័ព្ទ 012 588 060



ឯកឧត្តម កៅ ចេស្តា
អនុប្រធានសមាគមជាតិ
សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម
លេខទូរស័ព្ទ 011 858 859



លោកជំទាវ ប្រាក់ ពុទ្ធី
អនុប្រធានសមាគមជាតិ
សមាជិកាក្រុមប្រឹក្សាខេត្តស្វាយរៀង
លេខទូរស័ព្ទ 012 924 008



ឯកឧត្តម ចិន ញៀន
អនុប្រធានសមាគមជាតិ
សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ
លេខទូរស័ព្ទ 017 249 811



ឯកឧត្តម ផន ប៊ុន
អនុប្រធានសមាគមជាតិ
សមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ
លេខទូរស័ព្ទ 092 631 718

# សមាសភាពគណៈកម្មការរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត

| | គោត្តនាម-នាម | តួនាទីក្រុមប្រឹក្សា | តួនាទីគណៈកម្មការ | លេខទូរស័ព្ទ |
|---|---|---|---|---|
| **១. គណៈកម្មការទំនាក់ទំនងសាធារណៈ** | | | | |
| ១ | ឯកឧត្តម យឹម សុខុម | ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ | ប្រធាន | 012 811 117 |
| ២ | ឯកឧត្តម កៅ ចេស្តា | សមាជិកក្រុមប្រឹក្សាខេត្តកំពង់ចាម | អនុប្រធាន | 011 858 859 |
| ៣ | ឯកឧត្តម ស្រី គឹមយូ | សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ | អនុប្រធាន | 012 827 765 |
| ៤ | លោកជំទាវ អ៊ីវ តារា | សមាជិកាក្រុមប្រឹក្សាខេត្តបាត់ដំបង | សមាជិក | 097 6363 327 |
| ៥ | លោកជំទាវ គុង ណារី | សមាជិកាក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង | សមាជិក | 012 553 522 |
| ៦ | ឯកឧត្តម លាត ភិរុណ | សមាជិកក្រុមប្រឹក្សាខេត្តព្រៃវែង | សមាជិក | 031 4444 842 |
| ៧ | ឯកឧត្តម សាម សុជាង | សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប | សមាជិក | 012 532 253 |
| ៨ | លោកជំទាវ គួច ចន្ថា | សមាជិកាក្រុមប្រឹក្សាខេត្តព្រះសីហនុ | សមាជិក | 016 641 592 |
| ៩ | ឯកឧត្តម រាណ សុវណ្ណរិទ្ធិ | សមាជិកក្រុមប្រឹក្សាខេត្តស្វាយរៀង | សមាជិក | 097 678 1400 |
| ១០ | ឯកឧត្តម ម៉ៅ សាន | សមាជិកក្រុមប្រឹក្សាខេត្តពោធិ៍សាត់ | សមាជិក | 012 837 927 |
| ១១ | ឯកឧត្តម ចាប ម៉ុច | សមាជិកក្រុមប្រឹក្សាខេត្តកណ្តាល | សមាជិក | 012 970 816 |
| **២. គណៈកម្មការអភិវឌ្ឍន៍សមត្ថភាព** | | | | |
| ១ | លោកជំទាវ មុំ ក្រសាល | សមាជិកាក្រុមប្រឹក្សារាជធានីភ្នំពេញ | ប្រធាន | 012 805 471 |
| ២ | លោកជំទាវ ប្រាក់ ពុទ្ធី | សមាជិកាក្រុមប្រឹក្សាខេត្តស្វាយរៀង | អនុប្រធាន | 012 924 008 |
| ៣ | ឯកឧត្តម ឯម ដេត | សមាជិកក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ | អនុប្រធាន | 017 248 881 |
| ៤ | លោកជំទាវ សុខ ចន្ធធូ | សមាជិកាក្រុមប្រឹក្សាខេត្តកំពង់ធំ | សមាជិក | 092 277 881 |
| ៥ | ឯកឧត្តម អេ សារុម | សមាជិកក្រុមប្រឹក្សាខេត្តបាត់ដំបង | សមាជិក | 012 994 109 |
| ៦ | ឯកឧត្តម ញ៉ូវ សាឯម | សមាជិកក្រុមប្រឹក្សាខេត្តកំពត | សមាជិក | 012 691 832 |
| ៧ | លោកជំទាវ លឹម សុខន | សមាជិកាក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ | សមាជិក | 012 916 981 |
| ៨ | លោកជំទាវ ជឹម សារីន | សមាជិកាក្រុមប្រឹក្សាខេត្តព្រៃវែង | សមាជិក | 017 775 767 |
| ៩ | ឯកឧត្តម ឈា ផល្លី | សមាជិកក្រុមប្រឹក្សាខេត្តក្រចេះ | សមាជិក | 011 241 545 |
| ១០ | ឯកឧត្តម ចយ សុបិន | សមាជិកក្រុមប្រឹក្សាខេត្តកណ្តាល | សមាជិក | 012 970 975 |
| ១១ | ឯកឧត្តម ហេង ស៊ី | សមាជិកក្រុមប្រឹក្សាខេត្តព្រះសីហនុ | សមាជិក | 016 527 070 |
| **៣. គណៈកម្មការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ (គ.ទ.ស.ក)** | | | | |
| ១ | លោកជំទាវ នួន នារតី | សមាជិកាក្រុមប្រឹក្សាខេត្តកណ្តាល | ប្រធាន | 012 777 521 |
| ២ | លោកជំទាវ ស៊ិន ណម | សមាជិកាក្រុមប្រឹក្សាខេត្តសៀមរាប | អនុប្រធាន | 017 310 323 |
| ៣ | ឯកឧត្តម សុខ យ៉ាន | សមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ | អនុប្រធាន | 012 898 464 |
| ៤ | លោកជំទាវ ចន្ទ សេង | សមាជិកាក្រុមប្រឹក្សាខេត្តស្វាយរៀង | សមាជិក | 012 637 963 |
| ៥ | លោកជំទាវ យួន គឹមនី | សមាជិកាក្រុមប្រឹក្សារាជធានីភ្នំពេញ | សមាជិក | 097 8898 998 |
| ៦ | លោកជំទាវ ខូយ ប៊ុនថាន | សមាជិកាក្រុមប្រឹក្សាខេត្តព្រះវិហារ | សមាជិក | 088 8953 570 |
| ៧ | លោកជំទាវ កុត ប៊ុនមី | សមាជិកាក្រុមប្រឹក្សាខេត្តស្ទឹងត្រែង | សមាជិក | 097 677 5776 |
| ៨ | លោកជំទាវ អនហេង លក្ខិណា | សមាជិកាក្រុមប្រឹក្សាខេត្តកំពង់ចាម | សមាជិក | 012 862 206 |
| ៩ | លោកជំទាវ ញឹក សាគន្ធ | សមាជិកាក្រុមប្រឹក្សាខេត្តបាត់ដំបង | សមាជិក | 092 530 350 |
| ១០ | ឯកឧត្តម អ៊ុយ ខេមរា | សមាជិកក្រុមប្រឹក្សាខេត្តតាកែវ | សមាជិក | 012 668 005 |
| ១១ | ឯកឧត្តម កែម សុធឿន | សមាជិកក្រុមប្រឹក្សាខេត្តពោធិ៍សាត់ | សមាជិក | 012 627 377 |

*សេចក្តីសម្រេចចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

# ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អាណត្តិទី៣ ឆ្នាំ២០១៩-២០២៤



**ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ** មានសមាជិកក្រុមប្រឹក្សាចំនួន ២៥ រូប (ស្ត្រី ៦ រូប)
ឯកឧត្តម **ខេង ស៊ុម** ប្រធានក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ លេខទូរស័ព្ទ 012 630 011
លោកជំទាវ ភិន វង្ស ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 096 999 7557
លោក ព្រុំ កែវ ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 011 681 945



**ក្រុមប្រឹក្សាខេត្តបាត់ដំបង** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៥ រូប)
ឯកឧត្តម **អ៊ុយ រី** ប្រធានក្រុមប្រឹក្សាខេត្តបាត់ដំបង លេខទូរស័ព្ទ 012 508 180
លោកជំទាវ ញ៉ឹក សាគន្ធ ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 530 350
លោក សេង ប៉ោជិញ ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 777 770



**ក្រុមប្រឹក្សាខេត្តកំពង់ចាម** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៤ រូប)
ឯកឧត្តម **ខ្លូត ផន** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ចាម លេខទូរស័ព្ទ 012 823 925
លោកជំទាវ អនហេង លក្ខិណា ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 862 206
លោក លាង ដាវីត ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 077 799 090



**ក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង** មានសមាជិកក្រុមប្រឹក្សាចំនួន ២៣ រូប (ស្ត្រី ៤ រូប)
ឯកឧត្តម **ឡុង ឈុនឡៃ** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង លេខទូរស័ព្ទ 012 791 694
លោកជំទាវ តុង ណារី ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 553 522
លោក ហង់ សារ៉ន ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 363 225



**ក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ** មានសមាជិកក្រុមប្រឹក្សាចំនួន ២៥ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **យឹម សុខុម** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ លេខទូរស័ព្ទ 012 811 117
លោកជំទាវ កែវ សុខុម ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 096 478 5536
លោក ស្រី វ៉េត ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 016 743 072



**ក្រុមប្រឹក្សាខេត្តកំពង់ធំ** មានសមាជិកក្រុមប្រឹក្សាចំនួន ២៥ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **ឈុន ឈន់** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ លេខទូរស័ព្ទ 012 998 818
លោកជំទាវ សុខ ចន្ធូ ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 277 881
លោកស្រី សុទ្ធ ម៉ានីឡា អនុប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 078 907 616



**ក្រុមប្រឹក្សាខេត្តកំពត** មានសមាជិកក្រុមប្រឹក្សាចំនួន ២៥ រូប (ស្ត្រី ៤ រូប)
ឯកឧត្តម **ជឹង ផល្លា** ប្រធានក្រុមប្រឹក្សាខេត្តកំពត លេខទូរស័ព្ទ 017 372 777
លោកជំទាវ ទិត សេដ្ឋា ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 820 783
លោក ឯម ថានី ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 676 527



**ក្រុមប្រឹក្សាខេត្តកណ្ដាល** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៦ រូប)
ឯកឧត្តម **ម៉ៅ ភិរុណ** ប្រធានក្រុមប្រឹក្សាខេត្តកណ្ដាល លេខទូរស័ព្ទ 012 230 360
លោកជំទាវ នួន នារតី ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 777 521
លោក សំ សុភក្តិ ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 794 544



**ក្រុមប្រឹក្សាខេត្តកោះកុង** មានសមាជិកក្រុមប្រឹក្សាចំនួន ១៩ រូប (ស្ត្រី ៤ រូប)
ឯកឧត្តម **កាយ សំរួម** ប្រធានក្រុមប្រឹក្សាខេត្តកោះកុង លេខទូរស័ព្ទ 097 981 3388
លោកជំទាវ សរ ស៊ីមអ៊ីម ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 010 962 626
លោក វង់ សុផល ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 749 9994



**ក្រុមប្រឹក្សាខេត្តក្រចេះ** មានសមាជិកក្រុមប្រឹក្សាចំនួន ២១ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **ហៀ ស៊ីយ៉ែម** ប្រធានក្រុមប្រឹក្សាខេត្តក្រចេះ លេខទូរស័ព្ទ 011 908 191
លោកជំទាវ ប៊ុន ស៊ីថូត ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 531 596
លោកស្រី ធូ ខេមី ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 088 829 0166



**ក្រុមប្រឹក្សាខេត្តមណ្ឌលគិរី** មានសមាជិកក្រុមប្រឹក្សាចំនួន ១៥ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **ម៉ែន ង៉ុយ** ប្រធានក្រុមប្រឹក្សាខេត្តមណ្ឌលគិរី លេខទូរស័ព្ទ 012 588 060
លោកជំទាវ ខៀវ ប៊ុនលីន ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 644 430
លោក ជ័យ វិជ្ជា ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 088 333 4588



**ក្រុមប្រឹក្សារាជធានីភ្នំពេញ** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៦ រូប)
ឯកឧត្តម **ប៉ា សុជាតិវង្ស** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ លេខទូរស័ព្ទ 077 775 757
លោកជំទាវ ឃួន គឹមនី ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សា លេខទូរស័ព្ទ 076/097 889 8998
លោក ជាង សុភ័ស្ស ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សា លេខទូរស័ព្ទ 085 527 627



**ក្រុមប្រឹក្សាខេត្តព្រះវិហារ** មានសមាជិកក្រុមប្រឹក្សាចំនួន ១៩ រូប (ស្ត្រី ២ រូប)
ឯកឧត្តម **ឡុង សុវណ្ណ** ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ លេខទូរស័ព្ទ 011 840 013/012 961 026
លោកជំទាវ ខូយ ប៊ុនថាន ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 088 895 3570
លោក អ៊ុន អទិត្យាវង្ស ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 088 842 8866



**ក្រុមប្រឹក្សាខេត្តព្រៃវែង** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៥ រូប)
ឯកឧត្តម **ស្បោង សារ៉ាត** ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង លេខទូរស័ព្ទ 011 965 656
លោកជំទាវ ងិន សុផាន់នី ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 011 916 060
លោកស្រី ឯក ច័ន្ទធីតា ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 822 5558



**ក្រុមប្រឹក្សាខេត្តពោធិ៍សាត់** មានសមាជិកក្រុមប្រឹក្សាចំនួន ២១ រូប (ស្ត្រី ២ រូប)
ឯកឧត្តម **ម៉ក់ រ៉ា** ប្រធានក្រុមប្រឹក្សាខេត្តពោធិ៍សាត់ លេខទូរស័ព្ទ 099 997 766
លោកជំទាវ ឈឹម ស៊ីណា ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 832 304
លោកស្រី ប៊ុន ចំប៉ី ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 092 814 374



**ក្រុមប្រឹក្សាខេត្តរតនគិរី** មានសមាជិកក្រុមប្រឹក្សាចំនួន ១៩ រូប (ស្ត្រី ២ រូប)
ឯកឧត្តម **ណាប់ ប៊ុនហេង** ប្រធានក្រុមប្រឹក្សាខេត្តរតនគិរី លេខទូរស័ព្ទ 012 958 318
លោកជំទាវ ចក់ មើល ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 088 224 5665
លោក ជុំ ជ័យជេដ្ឋ ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 937 3777



**ក្រុមប្រឹក្សាខេត្តសៀមរាប** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **អ៊ាន យុន** ប្រធានស្តីទី ក្រុមប្រឹក្សាខេត្តសៀមរាប លេខទូរស័ព្ទ 012 880 892
លោកជំទាវ ស៊ិន ណម ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 017 310 323
លោក គួច វារីថ្វា ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 823 451

# ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អាណត្តិទី៣ ឆ្នាំ២០១៩-២០២៤



**ក្រុមប្រឹក្សាខេត្តព្រះសីហនុ** មានសមាជិកក្រុមប្រឹក្សាចំនួន ១៩ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **ជាម ហ៊ីម** ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ លេខទូរស័ព្ទ 011 353 311
លោកជំទាវ ប្រាក់ ច័ន្ទសុខា ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 940 156
លោក ប៉ែន សុភាព ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 086 587 319



**ក្រុមប្រឹក្សាខេត្តស្ទឹងត្រែង** មានសមាជិកក្រុមប្រឹក្សាចំនួន ១៧ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **ឈាង ឡាក់** ប្រធានក្រុមប្រឹក្សាខេត្តស្ទឹងត្រែង លេខទូរស័ព្ទ 097 909 8333
លោកជំទាវ កុត ប៊ុនមី ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 677 5776
កញ្ញា ញូយ ចន្ទ្រា ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 729 9947



**ក្រុមប្រឹក្សាខេត្តស្វាយរៀង** មានសមាជិកក្រុមប្រឹក្សាចំនួន ២៣ រូប (ស្ត្រី ៧ រូប)
ឯកឧត្តម **ជុំ ហាត** ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង លេខទូរស័ព្ទ 097 451 7757
លោកជំទាវ ចន្ទ សេង ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 637 963
លោកស្រី សួស ចិត្រា ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 578 3537



**ក្រុមប្រឹក្សាខេត្តតាកែវ** មានសមាជិកក្រុមប្រឹក្សាចំនួន ២៧ រូប (ស្ត្រី ៥ រូប)
ឯកឧត្តម **យស ណាស៊ី** ប្រធានក្រុមប្រឹក្សាខេត្តតាកែវ លេខទូរស័ព្ទ 012 508 549
លោកជំទាវ លឹម ប៊ុនលី ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 012 720 539
លោក ដួង សោ ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 096 924 2831



**ក្រុមប្រឹក្សាខេត្តកែប** មានសមាជិកក្រុមប្រឹក្សាចំនួន ១៥ រូប (ស្ត្រី ១ រូប)
ឯកឧត្តម **សំ សារីន** ប្រធានក្រុមប្រឹក្សាខេត្តកែប លេខទូរស័ព្ទ 012 597 999
លោកជំទាវ ដួង កែវចិន្តា ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 010 999 710
លោក ឌុក ទិញ អនុប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 016 201 045



**ក្រុមប្រឹក្សាខេត្តប៉ៃលិន** មានសមាជិកក្រុមប្រឹក្សាចំនួន ១៥ រូប (ស្ត្រី ៣ រូប)
ឯកឧត្តម **ជា ចាន់ឌិន** ប្រធានស្តីទី ក្រុមប្រឹក្សាខេត្តប៉ៃលិន លេខទូរស័ព្ទ 097 9222 777
លោកជំទាវ ពៅ សុខ ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 016 552 333
លោក ស៊ុន គ្រឿង ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 066 689 889



**ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ** មានសមាជិកក្រុមប្រឹក្សាចំនួន ១៩ រូប (ស្ត្រី ៥ រូប)
ឯកឧត្តម **ស៊ី ប្រាសិទ្ធ** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ លេខទូរស័ព្ទ 011 419 999
លោកជំទាវ ស្វោម គឹមឡន ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 088 994 9797
លោកស្រី ស្រាង ធានី ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 097 645 3804



**ក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ** មានសមាជិកក្រុមប្រឹក្សាចំនួន ២៥ រូប (ស្ត្រី ៤ រូប)
ឯកឧត្តម **ស៊ាក ឡេង** ប្រធានក្រុមប្រឹក្សាខេត្តត្បូងឃ្មុំ លេខទូរស័ព្ទ 017 808 830
លោកជំទាវ ខៀវ សាមួន ប្រធាន គ.ក.ស.ក នៃក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 017 955 464
លោក ឈាន ប៊ុនឈឿន ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត លេខទូរស័ព្ទ 031 399 9930

# ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

| តួនាទី | អាណត្តិទី១ | អាណត្តិទី២ | អាណត្តិទី៣ | | | | អាណត្តិទី៤ | | |
|---|---|---|---|---|---|---|---|---|---|
| | គិតពីខែមីនា ២០០២ | គិតពីខែមករា ២០១១ | គិតពីខែមករា ២០១៤ | គិតពីខែមករា ២០១៥ | គិតពីខែមេសា ២០១៦ | គិតពីខែមេសា ២០១៧ | គិតពីខែមេសា ២០១៨ | គិតពីខែមេសា ២០១៩ | គិតពីខែមេសា ២០២០¹ |
| មេឃុំ ចៅសង្កាត់ | ១០០ ០០០ | ១៥០ ០០០ | ៣០០ ០០០ | ៤០០ ០០០ | ៧៥០ ០០០ | ៨៨០ ០០០ | ១ ០៣០ ០០០ | ១ ១១០ ០០០ | ១ ១១០ ០០០ |
| ជំទប់ ចៅសង្កាត់រង | ៨០ ០០០ | ១២០ ០០០ | ២៤០ ០០០ | ៣៥០ ០០០ | ៥៥០ ០០០ | ៦៥០ ០០០ | ៨០០ ០០០ | ៨៥០ ០០០ | ៨៧០ ០០០ |
| សមាជិកក្រុមប្រឹក្សា | ៧០ ០០០ | ១០០ ០០០ | ២០០ ០០០ | ៣០០ ០០០ | ៤៨០ ០០០ | ៥៧០ ០០០ | ៧០០ ០០០ | ៧៤០ ០០០ | ៧៦០ ០០០ |
| មេភូមិ | ៤០ ០០០ | ៦០ ០០០ | ១២០ ០០០ | ១៦០ ០០០ | ២០០ ០០០ | ២២៥ ០០០ | ២៥០ ០០០ | ៤០០ ០០០ | ៤៣០ ០០០ |
| អនុប្រធានភូមិ | ៣៥ ០០០ | ៥០ ០០០ | ១០០ ០០០ | ១៤០ ០០០ | ១៦០ ០០០ | ១៨០ ០០០ | ២០០ ០០០ | ២៨០ ០០០ | ៣១០ ០០០ |
| សមាជិកភូមិ | ២៥ ០០០ | ៤០ ០០០ | ៨០ ០០០ | ១២០ ០០០ | ១៤០ ០០០ | ១៦០ ០០០ | ១៨០ ០០០ | ២៥០ ០០០ | ២៨០ ០០០ |

| តួនាទី | អាណត្តិទី១ | អាណត្តិទី២ | | | | អាណត្តិទី៣ |
|---|---|---|---|---|---|---|
| | គិតពីខែកក្កដា ២០០៩ | គិតពីខែមេសា ២០១៦ | គិតពីខែមេសា ២០១៧ | គិតពីខែមេសា ២០១៨ | គិតពីខែមេសា ២០១៩ | គិតពីខែមេសា ២០២០¹ |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ ០០០ ០០០ | ១ ០៩០ ០០០ | ១ ២១០ ០០០ | ១ ៣៦០ ០០០ | ១ ៤៤០ ០០០ | ១ ៤៤០ ០០០ |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ៨០០ ០០០ | ៨៧០ ០០០ | ៩៧០ ០០០ | ១ ០៨៥ ០០០ | ១ ១៣៥ ០០០ | ១ ១៣៥ ០០០ |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៧០០ ០០០ | ៨១០ ០០០ | ៩៣៥ ០០០ | ១ ០៧៥ ០០០ | ១ ១៥៥ ០០០ | ១ ១៥៥ ០០០ |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៥០០ ០០០ | ៦៥០ ០០០ | ៧៥០ ០០០ | ៨៦០ ០០០ | ៩១០ ០០០ | ៩១០ ០០០ |

១. អនុក្រឹត្យលេខ៣៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

# ឯកឧត្តម ប៉ា សុជាតិវង្ស ចូលរួមថវិកាផ្ទាល់ខ្លួន ២ លានរៀល បន្ថែមលើថវិកា ៤ លានរៀល នៃមូលនិធិមរណសង្គ្រោះជូនក្រុមគ្រួសារសពសមាជិកក្រុមប្រឹក្សាដែលទទួលមរណភាព

ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានប្រកាសកាលពីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងកិច្ចប្រជុំគណៈ កម្មការទំនាក់ទំនងសាធារណៈ ថាឯកឧត្តមចូលរួមថវិកាផ្ទាល់ខ្លួនចំនួន ២ លានរៀល ជូនក្រុមគ្រួសារសពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងតំណែងដែលទទួលមរណភាព បន្ថែមលើថវិកា ៤ លានរៀល ក្នុងករណីជាសមាជិកមូលនិធិមរណសង្គ្រោះសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

ជាក់ស្តែង ថវិកា ២ លានរៀលនិងថវិកា ៤ លានរៀល ត្រូវបានប្រគល់ជូនក្រុមគ្រួសារសពឯកឧត្តម អ៊ឹង ហឿន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប ទទួលមរណភាពនាថ្ងៃទី២៣ វិច្ឆិកា និងគ្រួសារសពគ្រួសារសពឯកឧត្តម ជុន ម៉េង សមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ ទទួលមរណភាពនាថ្ងៃទី១៣ ធ្នូ ឆ្នាំ២០២០។

គិតត្រឹមថ្ងៃទី១៥ ធ្នូ ឆ្នាំ២០២០ នេះ ក្នុងចំណោមប្រធាន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៥៥៩ រូប, ៥៤៧ រូប បានស្ម័គ្រចិត្តចូលជាសមាជិកមូលនិធិ ហើយអតីតប្រធាននិងសមាជិកក្រុមប្រឹក្សាចំនួន ៣៤ រូប នៅបន្តបង់ប្រាក់ជាសមាជិកមូលនិធិ។



*ថវិកា និងលិខិតរំលែកទុក្ខប្រគល់ជូនគ្រួសារសពឯ.ឧ អ៊ឹង ហឿន។*

សមាជិកមូលនិធិមរណសង្គ្រោះរួមមាន៖ សមាជិកក្រុមប្រឹក្សារាជធានី ខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអតីតសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលបាន នឹងកំពុងបន្តបង់ប្រាក់ជូនដល់មូលនិធិមរណសង្គ្រោះ។

មូលនិធិមរណសង្គ្រោះក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានបង្កើតឡើងដោយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត នៅខែវិច្ឆិកា ឆ្នាំ២០១៤ ក្នុងគោលបំណងជួយសម្រាលនូវទុក្ខលំបាកទាំងខាងផ្លូវចិត្ត និងផ្លូវសម្ភារៈ ដល់ស្វាមីឬភរិយារបស់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត នៅពេលទទួលមរណភាព។

នៅពេលសមាជិកមរណសង្គ្រោះទទួលមរណភាព ក្រុមគ្រួសារនឹងទទួលបានថវិកាចំនួន **៤ លានរៀល**។ ក្នុងករណីសហព័ទ្ធទទួលមរណភាព សមាជិកនឹងទទួលបានថវិកាចំនួន **៣ លានរៀល**។ នៅពេលមានសមាជិកក្រុមប្រឹក្សាទទួលមរណភាព នោះសមាជិកមូលនិធិ ត្រូវបង់ប្រាក់ចំនួន **១៥ ០០០ រៀល**។ ហើយ នៅពេលសហព័ទ្ធរបស់សមាជិកក្រុមប្រឹក្សា ទទួលមរណភាព សមាជិកមូលនិធិត្រូវបង់ប្រាក់ចំនួន **១០ ០០០ រៀល**។

គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ នេះ មានសមាជិកមូលនិធិរណសង្គ្រោះចំនួន ៣១ រូប និងសហព័ទ្ធចំនួន ១៤ រូប បានទទួលមរណភាព៕ ឈឹម សុភាគ

# ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន អាណត្តិទី៣



ឯកឧត្តម សយ កុសល
ប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 077 444 480/016 558 080



លោក គង់ ឆេង
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 092 817 766



លោកស្រី ស៊ី តួន
អនុប្រធានអចិន្ត្រៃយ៍សម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 012 870 336



លោក យុង ហួត
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 012 329 427



លោក គៀង សេងគី
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 012 958 557



លោក សំរិទ្ធិ អេង
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 012 832 467



លោក ស៊ីវ យុត
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 012 985 687



លោក យស់ យឿន
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 092 330 181



លោកស្រី ហេង ស្រីពៅ
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 095 674 333



លោក ម៉ាក សុខឿន
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 012 719 710/088 8719 710



លោកស្រី ខាញ់ សូរី
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 097 7600 650/097 433 0540



លោក ពៅ បឿន
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 011 427 886



លោក សុខ រស្មី
អនុប្រធានសម្ព័ន្ធភាពជាតិ
លេខទូរស័ព្ទ 092 404 407

# សមាសភាពគណៈកម្មការរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

| | គោត្តនាម-នាម | តួនាទីសមាគមក្រុមប្រឹក្សា | តួនាទីគណៈកម្មការ | លេខទូរស័ព្ទ |
|---|---|---|---|---|
| **១. គណៈកម្មការកសាងសមត្ថភាព និងអភិវឌ្ឍន៍ស្ថាប័ន (គណៈកម្មការទី១)** | | | | |
| ១ | លោក យុង ហួត | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | ប្រធាន | 012 329 427 |
| ២ | លោក ពៅ បឿន | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 011 427 886 |
| ៣ | លោកស្រី ហេង ស្រីពៅ | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 095 674 333 |
| ៤ | លោក យឹម សាភាន់ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តព្រៃវែង | សមាជិក | 012 880 251 |
| ៥ | លោក តូច សាម៉ន | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកែប | សមាជិក | 012 956 595 |
| ៦ | លោក ជុំ ទ្រូក | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ស្ពឺ | សមាជិក | 012 866 575 |
| ៧ | លោក ហ៊ឹម ស្រេង | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តក្រចេះ | សមាជិក | 012 426 609 |
| ៨ | លោក ជាម សុខ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តបន្ទាយមានជ័យ | សមាជិក | 012 912 628 |
| ៩ | លោក អុំ សារ៉ាន់ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តមណ្ឌលគិរី | សមាជិក | 012 461 638 |
| ១០ | លោកស្រី ម៉ែន សុភី | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តស្វាយរៀង | សមាជិក | 088 958 4030 |
| ១១ | លោកស្រី វ៉ាន់ តាំងអ៊ី | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តត្បូងឃ្មុំ | សមាជិក | 071 575 0707 |
| **២. គណៈកម្មការកសាងភាពជាដៃគូ ឥស្សរជន និងទំនាក់ទំនងសាធារណៈ (គណៈកម្មការទី២)** | | | | |
| ១ | លោក គង់ ឆេង | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | ប្រធាន | 092 817 766 |
| ២ | លោក ស៊ីវ យុត | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 012 985 687 |
| ៣ | លោក សុខ រស្មី | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 092 404 407 |
| ៤ | លោក មាស ទូក | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ចាម | សមាជិក | 012 993 167 |
| ៥ | លោក ទុន ពៅ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តរតនគិរី | សមាជិក | 097 999 8688 |
| ៦ | លោក សាម ឡុន | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តសៀមរាប | សមាជិក | 092 906 343 |
| ៧ | លោក លី ទិត | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តស្ទឹងត្រែង | សមាជិក | 011 935 109 |
| ៨ | លោក សុខ សំអុល | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តស្វាយរៀង | សមាជិក | 097 731 6302 |
| ៩ | លោកស្រី ញាណ ពុយភិរុណ | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តក្រចេះ | សមាជិក | 092 467 114 |
| ១០ | លោកស្រី សុខ សុភាព | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តបាត់ដំបង | សមាជិក | 089 545 956 |
| ១១ | កញ្ញា វង្ស ផល្លា | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ស្ពឺ | សមាជិក | 070 307 504 |
| **៣. គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ (គណៈកម្មការទី៣)** | | | | |
| ១ | លោកស្រី ស៊ុ តូន | អនុប្រធានអចិន្ត្រៃយ៍សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | ប្រធាន | 012 870 336 |
| ២ | លោកស្រី ខាញ់ ស្ងួរី | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 097 433 0540 |
| ៣ | លោក ម៉ាក សុខឿន | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 012 719 710 |
| ៤ | លោកស្រី នី វ៉ាទី | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តព្រះសីហនុ | សមាជិក | 011 225 538 |
| ៥ | លោក សួន ប៊ុនសង | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តប៉ៃលិន | សមាជិក | 071980 5000 |
| ៦ | លោកស្រី ឮ ចិន្តា | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តសៀមរាប | សមាជិក | 012 235 659 |
| ៧ | លោកស្រី យ៉ែម សំអើន | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពត | សមាជិក | 092 607 652 |
| ៨ | លោកស្រី ហេង សុគន្ធារី | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តតាកែវ | សមាជិក | 012 420 311 |
| ៩ | លោកស្រី ង៉ែត វារីផល | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ឆ្នាំង | សមាជិក | 077 872 781 |
| ១០ | លោកស្រី សោម សុខុម | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តព្រះវិហារ | សមាជិក | 087 513 336 |
| ១១ | លោក អៀង សុខុម | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តព្រៃវែង | សមាជិក | 097 367 2522 |

*សេចក្តីសម្រេចលេខ ០០១/២០ ស.ស.រ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។*

# ក្រុមសវនកម្មរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

| | គោត្តនាម-នាម | តួនាទីសមាគមក្រុមប្រឹក្សា | តួនាទីក្រុមសវនកម្ម | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | លោក គៀង សេងគី | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | ប្រធាន | 012 958 557 |
| ២ | លោក សំរិទ្ធិ អេង | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 012 832 467 |
| ៣ | លោក យស់ យឿន | អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | អនុប្រធាន | 092 330 181 |
| ៤ | លោក ម៉ៅ ប៉ោ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានីភ្នំពេញ | សមាជិក | 077 352 526 |
| ៥ | លោក សាន ខុន | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តតាកែវ | សមាជិក | 088 755 9933 |
| ៦ | លោក ចា ឡាន់ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកោះកុង | សមាជិក | 016 228 016 |
| ៧ | លោកស្រី មាស សិទ្ធី | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តព្រៃវែង | សមាជិក | 012 226 269 |
| ៨ | លោក អ៊ុំ ចន | អនុប្រធានអចិន្ត្រៃយ៍សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកណ្តាល | សមាជិក | 095 424 232 |
| ៩ | លោក ផ្លោក សុវណ្ណ | អនុប្រធានអចិន្ត្រៃយ៍សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ចាម | សមាជិក | 011 893 092 |
| ១០ | លោកស្រី ជា គឹមហុង | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ធំ | សមាជិក | 012 375 832 |
| ១១ | លោកស្រី កង ប៊ុនគា | អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តពោធិ៍សាត់ | សមាជិក | 097 989 9923 |

*សេចក្តីសម្រេចលេខ ០០១/២០ ស.ស.រ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។*

# ក្រុមគ្រូឧទ្ទេសអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (LED) របស់សម្ព័ន្ធភាពជាតិសមាគម ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន)

| | គោត្តនាម-នាម | តួនាទីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | តួនាទីក្រុមគ្រូឧទ្ទេស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | លោក គង់ វ៉ាន់ | សមាជិកក្រុមប្រឹក្សាស្រុកកោះធំ ខេត្តកណ្តាល | ប្រធាន | 012 489 943 |
| ២ | លោក គៀង សេងគី | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ធំ | អនុប្រធាន | 012 958 557 |
| ៣ | លោក គង់ ឆេង | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកណ្តាល | សមាជិក | 092 817 766 |
| ៤ | លោក យ៉ុង ហួត | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តព្រះវិហារ | សមាជិក | 012 329 427 |
| ៥ | លោក ស៊ីវ យុត | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពត | សមាជិក | 012 985 687 |
| ៦ | លោក សំរិទ្ធិ អេង | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តពោធិ៍សាត់ | សមាជិក | 012 832 467 |
| ៧ | លោក ជាម សុខ | ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តបន្ទាយមានជ័យ | សមាជិក | 012 912 628 |
| ៨ | លោកស្រី ឈិត ណារី | សមាជិកក្រុមប្រឹក្សាក្រុងកំពង់ចាម ខេត្តកំពង់ចាម | សមាជិក | 012 366 735 |
| ៩ | លោក វ័ន្ន ដាស៊ីណង់ | អភិបាលស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ | សមាជិក | 012 500 083 |
| ១០ | លោកស្រី អៀង កណ្ណារ៉ា | អភិបាលរងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ | សមាជិក | 012 865 187 |
| ១១ | លោក លាង វាសនា | អភិបាលរងក្រុងបាត់ដំបង ខេត្តបាត់ដំបង | សមាជិក | 089 277 771 |
| ១២ | លោក ធុំ ឆាន | អភិបាលរងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ | សមាជិក | 012 450 030 |
| ១៣ | លោក ញឹម ធឿង | នាយករដ្ឋបាលក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ | សមាជិក | 012 902 414 |
| ១៤ | លោក នូ ចំរើន | នាយករងរដ្ឋបាលក្រុងបាត់ដំបង ខេត្តបាត់ដំបង | សមាជិក | 017 339 986 |
| ១៥ | លោក ណយ ចេក | អនុប្រធានការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាននិង សណ្តាប់ធ្នាប់សាធារណៈ នៃក្រុងបាត់ដំបង ខេត្តបាត់ដំបង | សមាជិក | 017 244 241 |
| ១៦ | លោក ខែម ពេជ្យរស្មី | អនុប្រធានការិយាល័យអភិវឌ្ឍក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ | សមាជិក | 092 760 350 |

*លក្ខខណ្ឌការងាររបស់ក្រុមគ្រូឧទ្ទេសអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ របស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។*

# សម្ព័ន្ធភាពជាតិបើកវគ្គជូនថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងផលិតវីដេអូមេរៀនស្តីពី "ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (LED)"

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានរៀបចំការបណ្តុះបណ្តាលរយៈពេលពីរថ្ងៃចំនួនពីរវគ្គស្តីពី "ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន" ជូនថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ២៥ រាជធានី ខេត្ត៖ វគ្គទី១ រៀបចំឡើងនាថ្ងៃទី១១-១២ ខែមិថុនា នៅខេត្តកំពត និងវគ្គទី២ នៅខេត្តក្រចេះថ្ងៃទី១-២ កក្កដា។

វគ្គទាំងពីរមានគោលបំណងលើកកម្ពស់ការយល់ដឹងរបស់ថ្នាក់ដឹកនាំអំពីការរៀបចំផែនការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការអភិវឌ្ឍអាជីវកម្មនិងការវិនិយោគ ទំនាក់ទំនងរវាងអាជ្ញាធរមូលដ្ឋាននិងអ្នកអនុវត្តការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

ផ្អែកលើបទពិសោធន៍នៃការបណ្តុះបណ្តាលខាងលើ សម្ព័ន្ធភាពជាតិបានជួលក្រុមហ៊ុនឯកជនឱ្យផលិតវីដេអូមេរៀន ៤ ខ្សែស្តីពី "ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន" ក្នុងគោលបំណងចែករំលែកចំណេះដឹងដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ការបណ្តុះបណ្តាលនិងការផលិតវីដេអូនេះធ្វើឡើងក្រោមការគាំទ្រពីសហព័ន្ធទីក្រុងនៃប្រទេសកាណាដា (FCM) តាមរយៈគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (PMI-LED)។

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ក្រុមគ្រូឧទ្ទេសអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់សម្ព័ន្ធភាពជាតិដែលមានសមាជិកចំនួន ១៦ រូប បានប្រជុំពិនិត្យ និងផ្តល់សុពលភាពខ្លឹមសារវីដេអូមេរៀនទាំង ៤ ខ្សែ គឺ៖ **ទី១** ជំហានទាំង ១២ នៃ LED ប្រកបដោយប្រសិទ្ធភាពនៅប្រទេសកម្ពុជា **ទី២** ទិដ្ឋភាពទូទៅនៃ LED **ទី៣** ការកសាងផែនការយុទ្ធសាស្ត្រ LED និង**ទី៤** គោលការណ៍នៃ LED។




ឯកឧត្តម សយ កុសល ដឹកនាំកិច្ចប្រជុំលើកទី៤ គណៈកម្មការគ្រប់គ្រងគម្រោង PMI-LED។

តាមរយៈគម្រោង PMI-LED នេះដែរ បាយការណ៍ស្តីពី "ការសិក្សាភាពជាដៃគូ និងការកៀរគរធនធាន" ត្រូវបានរៀបចំឡើងដោយទីប្រឹក្សាជាតិ ក្នុងគោលបំណងផ្សព្វផ្សាយដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការកៀរគរធនធានរបស់សមាគមដែលជាទីតំបុគ្គលតំណាងឱ្យសំឡេងនិងការពារផលប្រយោជន៍ស្របច្បាប់របស់ក្រុមប្រឹក្សាជាសមាជិក៕

# សម្ព័ន្ធភាពជាតិរៀបចំការបណ្តុះបណ្តាលចំនួន ០៣ វគ្គ ពង្រឹងសមត្ថភាពលេខាធិការសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ២៥ រាជធានី ខេត្ត

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន កាលពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ២០២០ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការងារលេខាធិការ" ដើម្បីពង្រឹងសមត្ថភាពលេខាធិការ និងជំនួយការសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់មកពី ២៥ រាជធានី ខេត្ត ដែលជាវគ្គលើកទី៣ រៀបចំក្រោមការគាំទ្រពី EU តាមរយៈសមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង (AIMF)។

វគ្គបណ្តុះបណ្តាលលើកទី២ ស្តីពី "ការគ្រប់គ្រងរដ្ឋបាល និងការសរសេររបាយការណ៍" ត្រូវបានរៀបចំឡើងនាថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០២០។

វគ្គបណ្តុះបណ្តាលលើកទី១ ស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចបញ្ជីការគណនេយ្យ" ត្រូវបានរៀបចំឡើងនាថ្ងៃទី ០៩-១០ មីនា ឆ្នាំ២០២០ ក្នុងគោលបំណងពង្រឹងសមត្ថភាពលេខាធិការសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់មកពី ២៥ រាជធានី ខេត្ត នៅក្នុងការគ្រប់គ្រងប្រភពធនធាននានារបស់សមាគមប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ក្រៅពីថវិកាគាំទ្រពីដៃគូអភិវឌ្ឍន៍ ប្រភពចំណូលចំបងរបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បានមកពីប្រាក់សមាជិកភាពប្រចាំឆ្នាំ ២% នៃថវិកាផ្នែករដ្ឋបាល ដោយដកចេញបន្ទុកបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលជាសមាជិកសមាគម ផ្អែកលើលិខិតលេខ ០៥៤ សជណ/គ.ជ.អ.ប ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦៕



សិក្ខាកាមចូលរួមវគ្គទី៣ នៅអគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិ។ ឈឹម សុភាគ

# សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តកម្មវិធី "ពានរង្វាន់ឧត្តមភាពលើការងាររៀបចំតំបន់ប្រជុំជន" ជ្រើសរើសជ័យលាភីលេខ១ លេខ២ និងលេខ៣

សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមបានប្រកាសកម្មវិធី"ពានរង្វាន់ឧត្តមភាពលើ ការងាររៀ បចំតំបន់ប្រជុំជន" កាលពីខែមករា ឆ្នាំ ២០២០ ក្នុងគោលបំណងជ្រើសរើស និងទទួលស្គាល់គម្រោងដែលបានអនុវត្តរួចហើយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគំនិតច្នៃប្រឌិត នវានុវត្តន៍និងការអនុវត្តល្អលើការ រៀ បចំតំបន់ប្រជុំជននៅកម្ពុជា ដែលឆ្លើយតបទៅនឹងតម្រូវការ និងការប្រឈមប៉ះពាល់ដល់ជីវភាពអ្នករស់ ជាពិសេសសហគមន៍ក្រីក្រនៅតំបន់ប្រជុំជន។

ការអនុវត្តកម្មវិធីពានរង្វាន់ជាផ្នែកមួយនៃគម្រោង "ការពង្រឹងសមត្ថភាពអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា ក្នុងការរៀបចំផែនការនគរូបនីយកម្ម និងការគ្រប់គ្រងដីធ្លីដើម្បីកែប្រែមុខមាត់សហគមន៍មិនទាន់រៀបរយ និងធានាលទ្ធភាពក្នុងការទទួលបានសេវាសាធារណៈ ជាសារវ័ន្ត" អនុវត្តរួមគ្នាដោយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត, សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន, រដ្ឋបាលរាជធានីភ្នំពេញ, សាលាក្រុងប៉ារីស និងសមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង (AIMF) ក្រោមគាំទ្រពី EU។

នៅខែកក្កដា រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ចំនួន ៩ បានដាក់ពាក្យចូលរួមប្រកួតប្រជែង។ ក្រុមការងារបច្ចេកទេសនៃគម្រោងបានពិនិត្យ និងសំរាំងបញ្ជីខ្លីចំនួន ៧។ ក្រុមការងារបច្ចេកទេសបានចុះវាយតម្លៃដោយផ្ទាល់គម្រោងរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ទាំង ៧ ហើយបានជ្រើសរើសបេក្ខជនពាក់កណ្តាលផ្តាច់ព្រ័ត្រចំនួន ៥ ដើម្បីឱ្យគណៈកម្មការជ្រើសរើសជ័យលាភីពានរង្វាន់ ប្រជុំវាយតម្លៃជ្រើសរើសជ័យលាភី ០៣ ចុងក្រោយ។

ជាលទ្ធផល គណៈកម្មការដែលមានសមាសភាពចំនួន ៩រូប បានជួបប្រជុំកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ដើម្បីធ្វើការវាយតម្លៃបេក្ខជនពាក់កណ្តាលផ្តាច់ព្រ័ត្រទាំង ៥ តាមរយៈការ




*គណៈកម្មការជ្រើសរើសជ័យលាភីពានរង្វាន់ រៀបចំកិច្ចប្រជុំតាមអនឡាញ (Zoom) កាលពីថ្ងៃទី២០ តុលា ឆ្នាំ២០២០ ដើម្បីពិនិត្យបេក្ខជនពាក់កណ្តាលផ្តាច់ព្រ័ត្រសម្រាប់វាយតម្លៃជ្រើសរើសជ័យលាភី។* ឈឹម សុភាគ

ធ្វើបទបង្ហាញ និងការឆ្លើយតបសំណួរ។

**ជ័យលាភីលេខ ១** បានទៅលើគម្រោង "សាងសង់ទំបន់បង្ហៀរក្បាលហុងស៊ឹង ពោធិ៍សាត់" របស់រដ្ឋបាលក្រុងពោធិ៍សាត់ ទទួលបានពានរង្វាន់កិត្តិយសនិងម៉ូតូ១ គ្រឿង។

**ជ័យលាភីលេខ ២** បានទៅលើគម្រោងយុទ្ធនាការ "ផ្ទះ១ អំពូល១" របស់រដ្ឋបាលស្រុកបន្ទាយស្រី ខេត្តសៀមរាប ទទួលបានពានរង្វាន់ និងកុំព្យូទ័រយួរដៃ ១ គ្រឿង។

**ជ័យលាភីលេខ ៣** បានទៅលើគម្រោង "អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុងសហគមន៍ភូមិ១៥-១៦" របស់រដ្ឋបាលសង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទទួលបានពានរង្វាន់និងកុំព្យូទ័រលីតុ ១ គ្រឿង។

គម្រោងពីរទៀតដែលមិនបានជាប់ជ័យលាភីពានរង្វាន់គឺ៖ ១. គម្រោង "អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុងលានស្រូវនិងប្រព័ន្ធលូ" របស់រដ្ឋបាលសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ២. គម្រោង "សាងសង់លូរំដោះទឹក" របស់រដ្ឋបាលឃុំពន្លៃ ស្រុកអង្គរបុរី ខេត្តតាកែវ ទទួលបានរង្វាន់លើកទឹកចិត្ត គឺវិញ្ញាបនបត្រលើកទឹកចិត្តថ្នាក់ជាតិ។

កម្មវិធីប្រគល់ពានរង្វាន់ថ្នាក់ជាតិនឹងរៀបចំឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាជាតិរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។

គណៈកម្មការជ្រើសរើសជ័យលាភីពានរង្វាន់មានសមាសភាពចំនួន ៩ រូប៖

១. ឯកឧត្តម សយ កុសល ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន

២. ឯកឧត្តម អ៊ឹង ចិន្តា អគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី នៃព្រឹទ្ធសភា

៣. ឯកឧត្តម ងួន សុភ: សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ

៤. លោក ស៊ឹម រិទ្ធី អនុប្រធាននាយកដ្ឋានកិច្ចការក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ

៥. លោក ប៉ុល ចាន់ថន អនុប្រធាននាយកដ្ឋាននគរូបនីយកម្មនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

៦. លោក ស៊ិន បូរណ៍មី នាយកទីចាត់ការរៀបចំក្រុងនៃរដ្ឋបាលរាជធានីភ្នំពេញ

៧. លោកស្រី Elodie Cuenca មន្ត្រីសាលាក្រុងប៉ារីស

៨. លោក Laurent Jaboeuf មន្ត្រី AIMF

៩. លោកស្រី ប៊ី សុគន្ធា តំណាងប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា៕

# ក្រុមការងារអន្តរក្រសួងត្រូវបានបង្កើតដើម្បីពិនិត្យ និងដាក់បញ្ចូលវិធានការអនាម័យ និងបរិស្ថានទៅក្នុងលក្ខណសម្បត្តិនៃគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព

ក្រុមការងារអន្តរក្រសួងដើម្បីពិនិត្យ និងដាក់បញ្ចូលវិធានការអនាម័យ និងបរិស្ថានទៅក្នុងលក្ខណសម្បត្តិនៃគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ត្រូវបានបង្កើតឡើងរវាងក្រសួងមហាផ្ទៃនិងក្រសួងបរិស្ថាន តាមរយៈប្រកាសអន្តរក្រសួងលេខ៤៧១៣ ចុះថ្ងៃទី១០ ធ្នូ ឆ្នាំ២០២០ និងប្រកាសលេខ៤៧២៨ សសរ ចុះថ្ងៃទី១៦ ធ្នូ ឆ្នាំ២០២០ ចុះហត្ថលេខាដោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ក្រុមការងារដែលមានសមាសភាពសរុបចំនួន ១៧ រូប ដឹកនាំដោយឯកឧត្តម ម៉ៅ ច័ន្ទតារា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មានតួនាទី ភារកិច្ច ពិនិត្យឡើងវិញនូវលក្ខណសម្បត្តិនៃគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពដើម្បីធ្វើការកែសម្រួល ឱ្យបានសមស្របជាមួយនឹងសភាពការណ៍វិវត្តនៃការប្រែប្រួលបទល្មើស និងការចូលរួមរបស់ប្រជាពលរដ្ឋ។

ជាមួយគ្នានោះ ក្រុមការងារមានតួនាទីសិក្សា ពិនិត្យ និងកែសម្រួលគោលការណ៍វិធានការ និងយន្តការនានានៃចលនាប្រលងប្រណាំងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីធ្វើរបាយការណ៍អំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវដាក់ជូនរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច។

របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ គូសបញ្ជាក់ជារួមថា ការចាត់តាំងអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" បានដំណើរការយ៉ាងសកម្មភាព និងទទួលបានការគាំទ្រពីប្រជាពលរដ្ឋកាន់តែច្រើនឡើងនៅគ្រប់មូលដ្ឋាន ហើយសក្តីកម្មដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃគោលនយោបាយនេះ គឺនៅក្នុងឆ្នាំ ២០១៩ ចំណាត់ថ្នាក់លេខ ១ បានកើនឡើង ១៤៥ ឃុំ សង្កាត់ ស្មើនឹង ១៣% ខណៈដែលឃុំ សង្កាត់គ្មានចំណាត់ថ្នាក់ នៅសល់ត្រឹម ០៣ ឃុំ សង្កាត់ ប៉ុណ្ណោះ។

របាយការណ៍នេះ ក៏បានលើកឡើងផងដែរថា **កម្លាំងប្រជាការពារ**បានបង្ហាញតួនាទីរបស់ខ្លួនយ៉ាងសំខាន់នៅក្នុងការរួមចំណែកជំរុញប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" និងជួយរំលែកបន្ទុកការងាររបស់នគរបាលប៉ុស្តិ៍រដ្ឋបាល ទាំងលើការងារសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងពិធីផ្សេងៗក្នុងសហគមន៍ ទាំងការផ្តល់ព័ត៌មានទាក់ទងនឹងបទល្មើសនានា និងការចូលរួមល្បាតយាមកាម ក្រោមការគ្រប់គ្រង ដឹកនាំដោយនគរបាលប៉ុស្តិ៍រដ្ឋបាលផងដែរ។

ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" ត្រូវបានដាក់ឱ្យអនុវត្តដោយលិខិតលេខ ០២០ ជក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការចាត់តាំងអនុវត្តគោលនយោបាយ "**ភូមិ ឃុំ មានសុវត្ថិភាព**" មានគោលបំណង៖ ១. បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាពជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ ឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឱ្យកាន់តែបានល្អប្រសើរថែមទៀត ២. បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចពីគ្រប់សមាសភាពផ្សេងៗ ទាំងក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូបដើម្បីកសាងបានជា**កម្លាំងសរុប វិធានការសរុប** ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

**ភូមិ ឃុំ មានសុវត្ថិភាព** គឺជាភូមិ ឃុំ ដែលមានលក្ខណសម្បត្តិ ៩ យ៉ាង៖ ១. គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ ២. គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ៣. គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ ៤. គ្មានក្មេងទំនើង ៥. គ្មានល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ៦. គ្មានគ្រោះថ្នាក់ចរាចរណ៍ ៧. គ្មានគ្រោះថ្នាក់ដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះ ៨. មានវិធានការទប់ស្កាត់ គ្រប់គ្រងនិងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព ៩. គ្មានការត្រួតពិនិត្យខុសច្បាប់។

ជាមួយគ្នានោះ នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០១៨ សណន ស្តីពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ (**ចលនាប្រជាការពារ**) ជាសកម្មភាពចូលរួមដោយស្ម័គ្រចិត្តក្នុងស្មារតីភ្ញាក់រលឹករបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដើម្បីរួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៅមូលដ្ឋានដែលគាត់រស់នៅ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាននោះ។

**ភារកិច្ច និងសិទ្ធិរបស់កម្លាំងប្រជាការពារ** ប្រជាការពារមានភារកិច្ចចូលរួមជាមួយកម្លាំងនគរបាល ឬកងរាជអាវុធហត្ថ ឬអាជ្ញាធររដ្ឋបាលដែនដី ក្នុងការយាមល្បាតការពារសន្តិសុខភូមិ ឃុំ សង្កាត់ ការពារកន្លែងកំសាន្តសប្បាយ ពិធីបុណ្យទាន ឬការរៀបចំសណ្តាប់ធ្នាប់នៅទីសាធារណៈ ណាមួយតាមការចាត់តាំងរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាននោះ។ ប្រជាការពារមានសិទ្ធិឃាត់ចាប់ជនប្រព្រឹត្តបទល្មើសជាក់ស្តែងនានាដើម្បីប្រគល់អោយនគរបាល ឬកងរាជអាវុធហត្ថ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដើម្បីចាត់ការតាមនីតិវិធីច្បាប់។ ប្រជាការពារពុំមានសិទ្ធិទទួលបាននូវការបំពាក់អាវុធដើម្បីធ្វើសកម្មភាពទេ។

ឈឹម សុភាគ

# សម្ព័ន្ធភាពជាតិគាំទ្រសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរៀបចំ "វេទិកាថ្នាក់ខេត្ត" និង "ការចុះប្រឹក្សាយោបល់"

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន តាមរយៈគម្រោង EU-AIMF បានគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុដល់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តបាត់ដំបង និងស្វាយរៀង រៀបចំ**វេទិកាថ្នាក់ខេត្ត**ស្តីពី "ការអនុវត្តមុខងារក្រុមប្រឹក្សា និងការរៀបចំនគរូបនីយកម្ម និងការគ្រប់គ្រងដីធ្លី" ដើម្បីប្រមូលបញ្ហាប្រឈមរបស់រដ្ឋបាលមូលដ្ឋាន និងសហគមន៍មិនទាន់រៀបរយ។

វេទិការៀបចំឡើងមានការចូលរួមពីស្ថាប័នព្រឹទ្ធសភា ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរពាក់ព័ន្ធ និងអ្នកសារព័ត៌មាន។ វេទិកានៅខេត្តបាត់ដំបងរៀបចំឡើងនាថ្ងៃទី២៨ ខែសីហា ក្រោមអធិបតីភាពឯកឧត្តម អ៊ុយ រី ប្រធានក្រុមប្រឹក្សាខេត្តបាត់ដំបង រីឯវេទិកានៅខេត្តស្វាយរៀង រៀបចំឡើងនាថ្ងៃទី៣ ខែវិច្ឆិកា ក្រោមអធិបតីភាពឯកឧត្តម ជុំ ហាត ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង។

ការរៀបចំវេទិកាគឺជាផ្នែកមួយនៃការអនុវត្តគម្រោង "ការពង្រឹងសមត្ថភាពអាជ្ញាធរថ្នាក់ក្រោមជាតិនៅកម្ពុជា ក្នុងការរៀបចំផែនការនគរូបនីយកម្មនិងការគ្រប់គ្រងដីធ្លី ដើម្បីកែប្រែមុខមាត់សហគមន៍មិនទាន់រៀបរយ និងជានាលទ្ធភាពក្នុងការទទួលបានសេវាសាធារណៈជាសារវ័ន្ត" ដែលអនុវត្តរួមគ្នាដោយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត, សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងរដ្ឋបាលរាជធានីភ្នំពេញ ក្រោមការគាំទ្រពី EU តាមរយៈសមាគមអន្តរជាតិអភិបាលក្រុងប្រើប្រាស់ភាសាបារាំង (AIMF)។

តាមរយៈគម្រោង EU-AIMF នេះដែរ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានគ្រោងទឹកប្រាក់ ៣៥០០ ដុល្លារ ដើម្បីគាំទ្រ "**ការចុះប្រឹក្សាយោបល់**" របស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ២៥ រាជធានី ខេត្ត។ ប៉ុន្តែ ចាប់តាំងពីខែឧសភា ឆ្នាំ២០២០ មកមានសមាគមចំនួន ១៥ ខេត្ត បានធ្វើសំណើសុំថវិកាមកសម្ព័ន្ធភាពជាតិ សម្រាប់អនុវត្តសកម្មភាពចុះប្រឹក្សាយោបល់នៅ ១៣៣ ឃុំ សង្កាត់ និង ០១ ស្រុក។ គិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា តាមរយៈការចុះប្រឹក្សាយោបល់នេះ បញ្ហាប្រឈម និងក្តីកង្វល់ចំនួន ៧០ ករណីត្រូវបានក្រុមប្រឹក្សាលើកឡើង ក្នុងនោះ ៥០ ករណីត្រូវបានស្រាយបំភ្លឺ និងផ្តល់យោបល់នៅហ្នឹងកន្លែងដោយថ្នាក់ដឹកនាំសមាគមនិងមន្ត្រីនៃទីចាត់ការផែនការនិងវិនិយោគ និងទីចាត់ការអន្តរវិស័យរបស់ខេត្តនីមួយៗ ហើយបញ្ហាសេសសល់ សមាគមនឹងខិតខំបន្ត។

ការចុះប្រឹក្សាយោបល់របស់សមាគមមានគោលបំណងលើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលជាសមាជិក តាមរយៈការកំណត់និងស្រាយបំភ្លឺបញ្ហា និងការផ្លាស់ប្តូរបទពិសោធន៍អំពីការអនុវត្តល្អដើម្បីទទួលបានវិធីសាស្ត្រថ្មីៗ សម្រាប់ដោះស្រាយ និងកាត់បន្ថយបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាក្នុងផ្តល់សេវាដល់ប្រជាពលរដ្ឋ និងជម្រុញការអភិវឌ្ឍមូលដ្ឋានកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។



នាថ្ងៃទី២១ ឧសភា ឆ្នាំ២០២០ ឯកឧត្តម សយ កុសល ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានបានដឹកនាំប្រតិភូនាំយកថវិកាសរុបចំនួន ៣៧ លានរៀល ប្រគល់ជូនគណៈកម្មការជាតិប្រឆាំងមេរោគកូវីដ-១៩ នៅក្រសួងសុខាភិបាល។ ថវិកានេះជាការចូលរួមបរិច្ចាកប្រាក់ឧបត្ថម្ភប្រចាំខែរបស់ថ្នាក់ដឹកនាំសម្ព័ន្ធភាពជាតិទាំង ១៣ រូប និងថវិកាចូលរួមរបស់ថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ២៥ រាជធានី ខេត្ត ដើម្បីរួមចំណែកជាមួយរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងមេរោគកូវីដ-១៩។ *ឈឹម សុភាគ*



នាថ្ងៃទី២-៣ ខែកញ្ញា ឆ្នាំ២០២០ វគ្គបណ្តុះបណ្តាលស្តីពី "ការប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យបរិស្ថាន" ត្រូវបានរៀបចំឡើងនៅខេត្តសៀមរាប សម្រាប់អ្នកចូលរួមចំនួន ២៥ រូប មកពីក្រុងស្រុកគោលដៅគម្រោង PMI-LED គឺក្រុងបាត់ដំបង ក្រុងសិរីសោភ័ណ ក្រុងប៉ោយប៉ែត ស្រុកមង្គលបូរី និងសាកលវិទ្យាល័យជាតិមានជ័យ។

ការបណ្តុះបណ្តាលរៀបចំដោយសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រុង ស្រុក ក្នុងការអនុវត្តសកម្មភាពគម្រោងមូលនិធិនៃគំនិតច្នៃប្រឌិត ដោយត្រូវគិតគូរ និងវាយតម្លៃពីផលប៉ះពាល់បរិស្ថាន។

វគ្គបណ្តុះបណ្តាលគាំទ្រដោយសហព័ន្ធទីក្រុងនៃប្រទេសកាណាដា (FCM) ជាផ្នែកមួយនៃគម្រោង "ភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (PMI-LED)" អនុវត្តពីឆ្នាំ២០១៦-២០២១ នៅ ៧ ប្រទេស រួមមានកម្ពុជា វៀតណាម កូដឌីវ័រ ម៉ាលី បៀគីណាហ្វាសូ បូលីវី និងនីការ៉ាហ្គ័រ។ គម្រោង PMI-LED មានគោលបំណងពង្រឹងសមត្ថភាពសមាគមអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានដើម្បីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

# សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ចាមសហការជាមួយរដ្ឋបាលខេត្ត រៀបចំវគ្គបណ្តុះបណ្តាលស្តីពី “ តួនាទី ភារកិច្ចក្នុងរចនាសម្ព័ន្ធថ្មីរបស់មន្ត្រីរដ្ឋបាលក្រុង ស្រុក ”

សមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពង់ចាម បានសហការជាមួយទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលខេត្តកំពង់ចាមបើកវគ្គរយៈពេលពីរថ្ងៃចំនួន ៧ វគ្គ រៀបចំពីថ្ងៃទី០៣ វិច្ឆិកា-១១ ធ្នូ ឆ្នាំ២០២០ ស្តីពី “តួនាទី ភារកិច្ចក្នុងរចនាសម្ព័ន្ធថ្មីរបស់មន្ត្រីរដ្ឋបាលក្រុង ស្រុក ”ជូនដល់សិក្ខាកាមសរុបចំនួន៩២០ រូប ក្នុងនោះ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ១៩៤ រូប និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុកចំនួន ៧២៦ រូប ដោយប្រើប្រាស់ថវិកាសមាគមប្រមាណ ២៧ លានរៀល។




ឯកឧត្តម អ៊ុន ចាន់ដា អភិបាលខេត្តកំពង់ចាមចូលរួមបើកវគ្គបណ្តុះបណ្តាល។

វគ្គបណ្តុះបណ្តាលនេះកើតឡើងតាមការណែនាំរបស់សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅក្នុងវគ្គបណ្តុះបណ្តាលនាថ្ងៃទី២២-២៣ កញ្ញា នៅខេត្តសៀមរាប សម្រាប់ថ្នាក់ដឹកនាំសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ២៥ រាជធានី ខេត្ត ស្តីពី “មុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ”។

លោក មាស ទូក ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តកំពង់ចាម មានប្រសាសន៍ថា ការបណ្តុះបណ្តាលទាំង ៧ វគ្គនេះ មានការគាំទ្រនិងយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ឯកឧត្តម អ៊ុន ចាន់ដា អភិបាលខេត្តកំពង់ចាម ដែលតម្រូវឱ្យសិក្ខាកាមចូលរួមពេញលេញ ករណីអវត្តមាន ត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់។

វគ្គនីមួយៗសម្របសម្រួលដោយគ្រូឧទ្ទេស ៥ រូប ផ្តោតទៅលើមេរៀនចំនួន ៥ គឺ៖ ១.ទិដ្ឋភាពទូទៅនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជា ២.រចនាសម្ព័ន្ធ និងតួនាទីភារកិច្ចនៃការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលក្រុង ស្រុក ៣.មុខងារនិងធនធានរបស់ក្រុង ស្រុក ៤. ទំនាក់ទំនងការងារនិងខ្សែរគណនេយ្យភាព និង ៥.របៀបរបការងាររបស់ការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលក្រុង ស្រុក។

ពិធីបិទវគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅក្រោមអធិបតីភាពអភិបាលរងខេត្ត ដោយសិក្ខាកាមដែលបានចូលរួមវគ្គបានពេញលេញ ទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាដែលចុះហត្ថលេខាដោយឯកឧត្តម អ៊ុន ចាន់ដា អភិបាលខេត្តកំពង់ចាម៕ លី ម៉េងគា

# ឆ្នាំ២០២០ គម្រោង EU ផ្តោតលើការពង្រឹងសមត្ថភាពសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ៦ ខេត្ត អំពីការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនង ការសិក្សាតាមអនឡាញ និងការអនុវត្តគម្រោងខ្នាតតូច

ឆ្នាំ២០២០ គម្រោង “លើកកម្ពស់សមត្ថភាពស្ថាប័ន និងការប្រតិបត្តិរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ” ដែលអនុវត្តនៅខេត្តពោធិ៍សាត់ បន្ទាយមានជ័យ កំពង់ធំ កំពង់ស្ពឺ កណ្តាលនិងកែប ផ្តោតលើការពង្រឹងសមត្ថភាពអង្គអភិបាលកិច្ចរបស់សមាគមអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការសិក្សាតាមប្រព័ន្ធអនឡាញ និងការអនុវត្តគម្រោងខ្នាតតូច ៣៧ គម្រោង។

លោក សំរិទ្ធិ អេង ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តពោធិ៍សាត់និងជាប្រធានគម្រោងថ្លែងថា គម្រោងបានជួយបំពាក់ឧបករណ៍ Webcam និង Digital TV នៅការិយាល័យសមាគមទាំង ៦ និងនៅក្រុង ស្រុកគោលដៅចំនួន ៣៧ បម្រើឱ្យការប្រជុំ និងការបណ្តុះបណ្តាល ព្រមទាំងជួយផងដែរ រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ និងផែនការតស៊ូមតិរបស់សមាគម។

គម្រោងបានបង្កើតកម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញសម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ដោយបានដាក់បញ្ចូល ៥ មេរៀន ២៨៥ ឯកសារ ១៣៦ វីដេអូ និង ១១៩ សំឡេង ពាក់ព័ន្ធទៅនឹងសមាគមក្រុមប្រឹក្សា ការសរសេររបាយការណ៍ ការសរសេរករណីសិក្សា ការត្រួតពិនិត្យ និងវាយតម្លៃ ការបង្កើតកម្រងសំណួរ និងការប្រមូលទិន្នន័យ។ល។

ដើម្បីពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សានៅក្នុងការបង្កើត និងគ្រប់គ្រងគម្រោង, គម្រោងផ្តួចផ្តើមខ្នាតតូចចំនួន ៣៧ ខុសៗគ្នា ត្រូវបានបង្កើតឡើងនៅក្រុង ស្រុកទាំង ៣៧ ដោយគម្រោងនីមួយៗមានទឹកប្រាក់ប្រមាណ ២០០០ ដុល្លារ ដែលផ្តល់ផលផ្ទាល់ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

សហភាពអឺរ៉ុប (EU) បានគាំទ្រគម្រោងនេះរយៈពេល ៣ ឆ្នាំ (២០១៩-២០២១) ក្នុងគោលបំណងបង្កើនសមត្ថភាពសមាគមអាជ្ញាធរមូលដ្ឋាន ៦ ខេត្ត និងសមាជិកសមាគមក្នុងខេត្តគោលដៅ ដើម្បីលើកកម្ពស់គណនេយ្យភាព តម្លាភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ថវិកាអនុវត្តគម្រោងសរុបជាង ៩៨ ម៉ឺនអឺរ៉ូ ក្នុងនោះ ៨០% គាំទ្រដោយEU រីឯ ២០% វិភាគទានពីសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានខេត្តពោធិ៍សាត់ និងអង្គការដៃគូអនុវត្តគម្រោងគឺ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) អង្គការ អេដ អេ អាក់ស្យុង (AEA) និងអ្នកពាក់ព័ន្ធ៕ ហែម ថារ៉ាន់

# ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត



លោក **ជាម សុខ** ប្រធានក្រុមប្រឹក្សាក្រុងសិរីសោភ័ណ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តបន្ទាយមានជ័យ រួមជាមួយអនុប្រធានចំនួន ៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ១៨២ សំឡេងទល់នឹងមិនគាំទ្រ ១៧ សំឡេង។

លោក **ជាម សុខ** ទូរស័ព្ទ 012 912 628 លេខាធិការ កញ្ញា **វឿន វណ្ណី** ទូរស័ព្ទ 096 383 7324

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តបន្ទាយមានជ័យ



លោក **យស់ យឿន** ចៅសង្កាត់រតនៈ នៃក្រុងបាត់ដំបង ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តបាត់ដំបង រួមជាមួយអនុប្រធានចំនួន ៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២៩៦ សំឡេងទល់នឹងមិនគាំទ្រ ០២ សំឡេង។

លោក **យស់ យឿន** ទូរស័ព្ទ 092 330 181 លេខាធិការ លោកស្រី **ឈុំ វិច្ឆិកា** ទូរស័ព្ទ 096 999 0876

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តបាត់ដំបង



លោក **មាស ទូក** ប្រធានក្រុមប្រឹក្សាស្រុកព្រៃឈរ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពង់ចាម រួមជាមួយអនុប្រធានចំនួន ១០ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៣៣៣ សំឡេង ទល់នឹងមិនគាំទ្រ ០១ សំឡេង។

លោក **មាស ទូក** ទូរស័ព្ទ 012 993 167 លេខាធិការ លោក **លី ម៉េងគា** ទូរស័ព្ទ 093 595 606

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តកំពង់ចាម



លោកស្រី **ភួន ឈុយអេង** ចៅសង្កាត់ផ្សារឆ្នាំង នៃក្រុងកំពង់ឆ្នាំង ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពង់ឆ្នាំង រួមជាមួយអនុប្រធានចំនួន ៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ១៤៣ សំឡេងទល់នឹងមិនគាំទ្រ ០៤ សំឡេង។

លោកស្រី **ភួន ឈុយអេង** ទូរស័ព្ទ 017 369 169 លេខាធិការ លោក **ស្រ៊ុន សុធី** ទូរស័ព្ទ 088 872 1525

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តកំពង់ឆ្នាំង



លោក **ជុំ ទ្រូក** ប្រធានក្រុមប្រឹក្សាស្រុកសំរោងទង ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពង់ស្ពឺ រួមជាមួយអនុប្រធានចំនួន ៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២២២ សំឡេងទល់នឹងមិនគាំទ្រ ០៤ សំឡេង។

លោក **ជុំ ទ្រូក** ទូរស័ព្ទ 097 991 8468/012 866 575 លេខាធិការ លោក **ជឹម សុខ** ទូរស័ព្ទ 016 587 955/012 360 928

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តកំពង់ស្ពឺ



លោក **គៀង សេងគី** មេឃុំត្បូងក្រពើ នៃស្រុកសន្ទុក ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពង់ធំ រួមជាមួយអនុប្រធានចំនួន ៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២២០ សំឡេងទល់នឹងមិនគាំទ្រ ០៥ សំឡេង។

លោក **គៀង សេងគី** ទូរស័ព្ទ 012 958 557 លេខាធិការ លោកស្រី **ហេង រតនា** ទូរស័ព្ទ 015 600 048

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តកំពង់ធំ



លោក **ស៊ីវ យុត** ចៅសង្កាត់ក្រាំងអំពិល នៃក្រុងកំពត ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកំពត រួមជាមួយអនុប្រធានចំនួន ១០ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រ ២១៨ លើ ២១៨ សំឡេង។

លោក **ស៊ីវ យុត** ទូរស័ព្ទ 012 985 687 លេខាធិការ លោកស្រី **ហេង ចន្ទីម** ទូរស័ព្ទ 017 445 958

អាសយដ្ឋានសមាគម ស្ថិតនៅសាលាសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត



លោក **គង់ ឆេង** មេឃុំគគីរ នៃស្រុកកៀនស្វាយ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកណ្តាល រួមជាមួយអនុប្រធានចំនួន ១០ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៣៤៩ សំឡេង ទល់នឹងមិនគាំទ្រ ០៣ សំឡេង។

លោក **គង់ ឆេង** ទូរស័ព្ទ 092 817 766 លេខាធិការ លោកស្រី **គីង សុភារី** ទូរស័ព្ទ 011 757 933

អាសយដ្ឋានសមាគម ស្ថិតនៅអគារមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល បរិវេណសាលាខេត្ត



លោក **ចា ឡាន់** ប្រធានក្រុមប្រឹក្សាស្រុកមណ្ឌលសីមា ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកោះកុង រួមជាមួយអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៨១ សំឡេងទល់នឹងមិនគាំទ្រ ០១ សំឡេង។

លោក **ចា ឡាន់** ទូរស័ព្ទ 016 228 016/097 555 3457 កញ្ញា **ងី មួយសៀន** ទូរស័ព្ទ 015 332 456

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តកោះកុង



លោក **ហ៊ឹម ស្រុង** ជំទប់ទី១ ឃុំសំបុក នៃស្រុកចិត្របុរី ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តក្រចេះ រួមជាមួយអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ១១៨ សំឡេងទល់នឹងមិនគាំទ្រ ០១ សំឡេង។

លោក **ហ៊ឹម ស្រុង** ទូរស័ព្ទ 012 426 609/097 742 6609 លេខាធិការ លោក **តិប ឆេង** ទូរស័ព្ទ 031 3666 960

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តក្រចេះ



លោក **អ៊ុំ សាវ៉ាន់** ប្រធានក្រុមប្រឹក្សាស្រុកពេជ្រាដា ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តមណ្ឌលគិរី រួមជាមួយអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៥៤ សំឡេងទល់នឹងមិនគាំទ្រ ០២ សំឡេង។

លោក **អ៊ុំ សាវ៉ាន់** ទូរស័ព្ទ 012 461 638 លេខាធិការ លោកស្រី **ជុំ ណារី** ទូរស័ព្ទ 011 338 477

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តមណ្ឌលគិរី



លោក **ម៉ៅ បូរ៉ា** ប្រធានក្រុមប្រឹក្សាខណ្ឌព្រែកព្នៅ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់ រាជធានីភ្នំពេញ រួមជាមួយអនុប្រធានចំនួន ១០ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៣៥៣ សំឡេងទល់នឹងមិនគាំទ្រ ០២ សំឡេង។

លោក **ម៉ៅ បូរ៉ា** ទូរស័ព្ទ 077 352 526 លេខាធិការ លោក **ជួន ភក្តី** ទូរស័ព្ទ 088 895 9095/017 949 094

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

# ប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាននៅតាមរាជធានី ខេត្ត



លោក **យុង ហួត** ប្រធានក្រុមប្រឹក្សាស្រុកជាំក្សាន្ត ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តព្រះវិហារ រួមជាមួយអនុប្រធានចំនួន ០៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២០៣ សំឡេងទល់នឹងមិនគាំទ្រ ០៧ សំឡេង។

លោក **យុង ហួត** ទូរស័ព្ទ 012 329 427/071 2555 000 លេខាធិការ លោក **ហ៊ីម កុម្ភៈ** ទូរស័ព្ទ 060 347 333

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តព្រះវិហារ



លោក **យឹម សាភាន់** មេឃុំឈើកាច់ នៃស្រុកបាភ្នំ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តព្រៃវែង រួមជាមួយអនុប្រធានចំនួន ០៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២៦០ សំឡេងទល់នឹងមិនគាំទ្រ ០៣ សំឡេង។

លោក **យឹម សាភាន់** ទូរស័ព្ទ 012 880 251 លេខាធិការ លោក **វង្ស សាវឿន** ទូរស័ព្ទ 011 482 648

អាសយដ្ឋានសមាគមៈ ស្ថិតក្នុងបរិវេណសាលាខេត្តព្រៃវែង



លោក **សំរិទ្ធិ អេង** ប្រធានក្រុមប្រឹក្សាក្រុងពោធិ៍សាត់ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តពោធិ៍សាត់ រួមជាមួយអនុប្រធានចំនួន ០៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២០៣ សំឡេងទល់នឹងមិនគាំទ្រ ០៧ សំឡេង។

លោក **សំរិទ្ធិ អេង** ទូរស័ព្ទ 012 832 467/097 291 5777 លេខាធិការ កញ្ញា **ហែម ផាវ៉ាន់** ទូរស័ព្ទ 092 911 665

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តពោធិ៍សាត់



លោក **ទុន ពៅ** ចៅសង្កាត់កាចាញ នៃក្រុងបានលុង ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តរតនគិរី រួមជាមួយអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ១០៥ សំឡេងទល់នឹងមិនគាំទ្រ ០២ សំឡេង។

លោក **ទុន ពៅ** ទូរស័ព្ទ 097 999 8688 លេខាធិការ លោក **ឆេញ រដ្ឋា** ទូរស័ព្ទ 097 560 5630

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តរតនគិរី



លោក **សាម ឡូន** ចៅសង្កាត់សាលាកំរើក នៃក្រុងសៀមរាប ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តសៀមរាប រួមជាមួយអនុប្រធានចំនួន ០៨ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២៦២ សំឡេងទល់នឹងមិនគាំទ្រ ០៤ សំឡេង។

លោក **សាម ឡូន** ទូរស័ព្ទ 092 906 343 លេខាធិការ លោក **ឈ ប៊ុនធឿន** ទូរស័ព្ទ 085 339 696/096 550 5336

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តសៀមរាប



លោកស្រី **នី វ៉ាទី** ជំទប់ទី១ ឃុំកំពេញ ស្រុកស្ទឹងហាវ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តព្រះសីហនុ រួមជាមួយអនុប្រធានចំនួន ០៤ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៩៧ សំឡេងទល់នឹងមិនគាំទ្រ ០១ សំឡេង។

លោកស្រី **នី វ៉ាទី** ទូរស័ព្ទ 011 225 538 លេខាធិការ កញ្ញា **ទី បូទាវ** ទូរស័ព្ទ 081 698 070

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តព្រះសីហនុ



លោក **លី ទិត** ប្រធានក្រុមប្រឹក្សាក្រុងស្ទឹងត្រែង ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តស្ទឹងត្រែង រួមជាមួយអនុប្រធានចំនួន ០៤ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៩១ សំឡេងទល់នឹងមិនគាំទ្រ ០៦ សំឡេង។

លោក **លី ទិត** ទូរស័ព្ទ 011 935 109 លេខាធិការ លោក **ដាំ សុវណ្ណារ៉ា** ទូរស័ព្ទ 097 432 2000

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តស្ទឹងត្រែង



លោក **សុខ សំអុល** ប្រធានក្រុមប្រឹក្សាស្រុកកំពង់រោទិ៍ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តស្វាយរៀង រួមជាមួយអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ១៨៤ សំឡេងទល់នឹងមិនគាំទ្រ ០១ សំឡេង។

លោក **សុខ សំអុល** ទូរស័ព្ទ 097 731 6302 លេខាធិការ លោក **គឹម សុភាព** ទូរស័ព្ទ 092 654 265

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តស្វាយរៀង



លោក **សាន ខុន** ប្រធានក្រុមប្រឹក្សាស្រុកទ្រាំង ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តតាកែវ រួមជាមួយអនុប្រធានចំនួន ១០ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ២០៣ លើ ២០៣ សំឡេង។

លោក **សាន ខុន** ទូរស័ព្ទ 088 755 9933 លេខាធិការ លោក **ឌិត សារ៉េត** ទូរស័ព្ទ 017 926 202/016 596 001

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តតាកែវ



លោក **តូច សាម៉ន** ចៅសង្កាត់ព្រៃធំ នៃក្រុងកែប ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តកែប រួមជាមួយអនុប្រធានចំនួន ០៤ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៥០ លើ ៥០ សំឡេង។

លោក **តូច សាម៉ន** ទូរស័ព្ទ 012 956 595/069 710 766 លេខាធិការ លោក **សៃ ពុទ្ធ** ទូរស័ព្ទ 088 400 9004

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប



លោក **សួន ប៊ុនសង** ប្រធានក្រុមប្រឹក្សាក្រុងប៉ៃលិន និងជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ខេត្តប៉ៃលិន។ សមាគមបានរៀបចំមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសប្រធាន០១ រូប និងអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៧១ លើ ៧១ សំឡេង។

លោក **សួន ប៊ុនសង** ទូរស័ព្ទ 071 980 5000 លេខាធិការ លោក **នួន ចាន់ធីរ៉ា** ទូរស័ព្ទ 097 555 6552

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណមន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន



លោក **ឡាយ ជឿន** មេឃុំជើងទៀន ស្រុកចុងកាល់ និងជាប្រធានស្តីទីសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តឧត្តរមានជ័យ។ សមាគមបានរៀបចំមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសប្រធាន០១ រូប និងអនុប្រធានចំនួន ០៦ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ៦០ លើ ៦០ សំឡេង។

លោក **ឡាយ ជឿន** ទូរស័ព្ទ 031 5344 888/060 958 855 លេខាធិការ លោក **ឡែម ឡុង** ទូរស័ព្ទ 097 466 4570

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តឧត្តរមានជ័យ



លោក **កាន់ គន់លី** សមាជិកក្រុមប្រឹក្សាស្រុកត្បូងឃ្មុំ ត្រូវបានមហាសន្និបាតអាណត្តិទី៣ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ បោះឆ្នោតជ្រើសរើសជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តត្បូងឃ្មុំ រួមជាមួយអនុប្រធានចំនួន ១០ រូបផ្សេងទៀត ដោយទទួលសន្លឹកឆ្នោតគាំទ្រចំនួន ១១៨ លើ ១១៨ សំឡេង។

លោក **កាន់ គន់លី** ទូរស័ព្ទ 092 918 227/031 4444 153 លេខាធិការ លោក **សុខ គឹមយ៉េង** ទូរស័ព្ទ 097 921 0097

អាសយដ្ឋានសមាគម ស្ថិតក្នុងបរិវេណសាលាខេត្តត្បូងឃ្មុំ

# សម្ព័ន្ធភាពជាតិបណ្តុះបណ្តាលថ្នាក់ដឹកនាំ សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានរាជធានី ខេត្ត អំពី "រចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ"



វគ្គបណ្តុះបណ្តាលរៀបចំនៅខេត្តសៀមរាបពីថ្ងៃទី២២-២៣ កញ្ញា ឆ្នាំ២០២០។ ឈឹម សុភាគ

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នាថ្ងៃទី២២-២៣ កញ្ញា បានរៀបចំវគ្គបណ្តុះបណ្តាលអំពី "អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ" ជូនប្រធាន-អនុប្រធានសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ២៥ រាជធានី ខេត្ត សរុប ៧០ រូប ក្រោមអធិបតីភាពឯកឧត្តម សយ កុសល ប្រធានសម្ព័ន្ធភាពជាតិ។

អនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានចុះហត្ថលេខាដោយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន** នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ បន្ទាប់មកពិធីផ្សព្វផ្សាយដាក់ឱ្យអនុវត្តត្រូវបានរៀបចំឡើងនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប។

សម្ព័ន្ធភាពជាតិបានរៀបចំបណ្តុះបណ្តាលស្តីពីអនុក្រឹត្យទាំង ៣ នេះ នៅខេត្តសៀមរាប ក្រោមការគាំទ្រពី EU តាមរយៈ សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង (AIMF) សម្របសម្រួលវគ្គដោយគ្រូឧទ្ទេសនៃលេខាធិការដ្ឋាន គ.ជ.អ.ប រួមមាន៖ ១. លោក ជ័យ សម្បត្តិផល្លា ប្រធានអង្គភាពវិភាពនិងអភិវឌ្ឍន៍គោលនយោបាយ ២. លោក ឈិន ទេពីរម្យ ទីប្រឹក្សា ៣. លោក ប៊ុន ម៉ានិត ប្រធានការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិ ៤. លោក ស៊ិន សុភ័ក្រ អនុប្រធានការិយាល័យអភិវឌ្ឍសមត្ថភាពថ្នាក់ក្រោមជាតិ។

ថ្លែងក្នុងពិធីបិទវគ្គ ឯកឧត្តម សយ កុសល បានស្នើឱ្យសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋានផ្សព្វផ្សាយបន្តដល់សមាជិកនូវអនុក្រឹត្យទាំង៣ និងបញ្ចប់ប្រកាសសាខាសមាគមថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០២០។

សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ឋានៈ អភិវឌ្ឍសមត្ថភាពនិងការពារផលប្រយោជន៍ស្របច្បាប់របស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេស។

# សមាគមជាតិបណ្តុះបណ្តាលគណៈកម្មការ អំពី "ការងារទំនាក់ទំនងសាធារណៈ និងជំនាញអ្នកនាំពាក្យ"



វគ្គបណ្តុះបណ្តាលរៀបចំនៅអគ្គលេខាធិការដ្ឋានសមាគមជាតិ ស្ថិតក្នុងព្រឹទ្ធសភា។ ឈឹម សុភាគ

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត នាថ្ងៃទី១០ ខែវិច្ឆិកា បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការងារទំនាក់ទំនងសាធារណៈ និងជំនាញអ្នកនាំពាក្យ" ដើម្បីលើកកម្ពស់សមត្ថភាពសមាជិកទាំង ១១ រូបរបស់គណៈកម្មការទំនាក់ទំនងសាធារណៈ។

ការរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រធានបទខាងលើផ្អែកទៅលើស្មារតីនៃកិច្ចប្រជុំលើកទី១ របស់គណៈកម្មការនៅថ្ងៃទី៨ ខែកញ្ញា ដែលនៅក្នុងកិច្ចប្រជុំនោះក៏បានពិនិត្យផងដែរយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្វែងរកការគាំទ្រផលប្រយោជន៍របស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្តនៅទូទាំងប្រទេស និងទិសដៅការងារគណៈកម្មការ។

ឯកឧត្តម យឹម សុខុម អនុប្រធានអចិន្ត្រៃយ៍សមាគមជាតិ និងជាប្រធានគណៈកម្មការទំនាក់ ទំនងសាធារណៈ គូសបញ្ជាក់ថា សមាគមជាតិបានឯកភាពជម្រុញការផ្សព្វផ្សាយអំពីគោលបំណងនៃការបង្កើតសមាគមជាតិដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងអ្នកពាក់ព័ន្ធ តាមរយៈ ការផលិតវីដេអូស្ពត និងការចាត់តាំងក្រុមអ្នកនាំពាក្យ។

ថ្លែងក្នុងពិធីបើកវគ្គ ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានសមាគមជាតិបានសង្កត់ធ្ងន់ថា ការងារទំនាក់ទំនងសាធារណៈ ពិតជាមានសារសំខាន់នៅក្នុងការលើកស្ទួយ និងកសាងកិត្តិនាមរបស់សមាគមជាតិនៅក្នុងចំណោមក្រុមគោលដៅ ដើម្បីស្វែងរកទំនុកចិត្តនិងការគាំទ្រផ្នែកហិរញ្ញវត្ថុ រួមទាំងផ្នែកស្មារតីនិងសំភារៈ ចំពោះបុព្វហេតុសមាគមជាតិ។

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៣ ជា "នីតិបុគ្គល" តំណាងឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងគោលបំណងដូចបានកំណត់ក្នុងលក្ខន្តិកៈ ៖ ទី១. លើកកម្ពស់ឋានៈ និងអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារាជធានី ខេត្ត ទី២.ការពារផលប្រយោជន៍និងគុណប្រយោជន៍ របស់សមាជិក និង ទី៣.កសាងភាពជាដៃគូជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍមូលដ្ឋាន ពង្រឹងនីតិរដ្ឋ និងជម្រុញលទ្ធិប្រជាធិបតេយ្យ នៅប្រទេសកម្ពុជា។ ឈឹម សុភាគ